ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ. ធ៧-០១៧-៣៤៤ ប្រ.ក

## ប្រកាស
## ស្តីពី
## ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមផែរមិន

---

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួល ប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់កាតព្វកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលតទៅនេះហៅថា "គ្រឹះស្ថាន" ក្នុងការអនុវត្តផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឥណទានដោយប្រុងប្រយ័ត្ន។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅបញ្ជាក់ពីភាពត្រឹមត្រូវនៃការទទួលស្គាល់ ការវាស់វែង ការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធី (Facilities) ដែលមានអ៊ីមផែរមិនរបស់គ្រឹះស្ថាន។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣**.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤**.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ហ្វាស៊ីលីធី (Facilities)** សំដៅដល់ប្រាក់កម្ចី និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ទាំងនៅក្នុងឬក្រៅតារាងតុល្យការ ដែលគ្រឹះស្ថានបានផ្តល់ទៅឲ្យសមភាគី ហើយហ្វាស៊ីលីធីនេះអាចបង្កហានិភ័យឥណទានដល់គ្រឹះស្ថាន។ បណ្តុំនៃហ្វាស៊ីលីធីទាំងអស់ដែលមានចែងក្នុងប្រកាសនេះ ហៅថា "សំពៀតឥណទាន"។
- **សមភាគី** សំដៅដល់ អតិថិជន អ្នកខ្ចីប្រាក់ ឬបុគ្គលផ្សេងទៀត រួមមាន រូបវន្តបុគ្គល ឬនីតិបុគ្គលមានទំនាក់ទំនងជាមួយគ្រឹះស្ថាន។ សមភាគីនេះ ក៏អាចជាគ្រឹះស្ថានផ្សេងទៀតដែលមានទំនាក់ទំនងសេដ្ឋកិច្ចជាមួយគ្នាផងដែរ។
- **ហានិភ័យឥណទាន** សំដៅដល់ហានិភ័យដែលសមភាគីមិនអាចអនុវត្តបានតាមកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យា។ ក្រៅពីកម្ចីដែលជាប្រភពចម្បងនៃហានិភ័យឥណទាន ប្រតិបត្តិការផ្សេងៗដែលមាននៅក្នុងបញ្ជិកាធនាគារ (Banking Book) និងបញ្ជិកាសម្រាប់ជួញដូរ (Trading Book) ទាំងក្នុងនិងក្រៅតារាងតុល្យការ ក៏ជាប្រភពនៃហានិភ័យឥណទានដែរ។ គ្រឹះស្ថានអាចប្រឈមនឹងហានិភ័យឥណទាន ដែលអាចកើតមកពីឧបករណ៍ហិរញ្ញវត្ថុនានាក្រៅពីប្រាក់កម្ចី ដូចជាការធ្វើស៊ីការ (Acceptances) ហិរញ្ញប្បទានពាណិជ្ជកម្ម ការសន្យាផ្តល់ឥណទាននិងការធានា ប្រតិបត្តិការអន្តរធនាគារ ប្រតិបត្តិការទូទាត់ ប្រតិបត្តិការប្តូរប្រាក់ សញ្ញាបណ្ណ មូលបត្រកម្មសិទ្ធិ និងឧបករណ៍និស្សន្ទ ជាដើម។
- **ទ្រព្យធានា** សំដៅដល់ ការធានា ទ្រព្យ ឬទ្រព្យសកម្ម ដែលសមភាគីបានដាក់ធានា ចំពោះហានិភ័យឥណទានរបស់គ្រឹះស្ថាន។
- **មូលធនកម្មការប្រាក់ (Interest Capitalization)** សំដៅដល់រាល់ការបង្គរការប្រាក់ និងការប្រាក់មិនអាចប្រមូលបានដែលត្រូវបូកបញ្ចូលក្នុងប្រាក់ដើមនៃឥណទាននៅថ្ងៃទូទាត់សងប្រាក់ ឬថ្ងៃឥណប្រតិទាន។ មូលធនកម្មការប្រាក់ក៏ត្រូវរួមបញ្ចូលផងដែរនូវការប្រាក់មិនបានទូទាត់ ហើយការប្រាក់នេះ ត្រូវបានប្រែក្លាយទៅជាប្រាក់កម្ចីថ្មី តាមរយៈការធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី។
- **ការខកខានទូទាត់សង (Default)** សំដៅដល់ការខកខានក្នុងការទូទាត់សងតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា។
- **តម្លៃជាក់ស្តែង (Fair Value)** សំដៅដល់តម្លៃដែលទទួលបានពីប្រតិបត្តិការលក់ទ្រព្យសកម្ម ឬតម្លៃដែលត្រូវចំណាយលើប្រតិបត្តិការផ្ទេរទ្រព្យអកម្មរវាងអ្នកចូលរួមនៅក្នុងទីផ្សារ នៅកាលបរិច្ឆេទទទួលស្គាល់តម្លៃនៃការទិញលក់។
- **អ៊ីមភែរមិន (Impairment)** សំដៅដល់ស្ថានភាពហ្វាស៊ីលីធីដែលស្ថិតក្នុងការសង្ស័យ ចំពោះលទ្ធភាពទូទាត់សងគ្រប់ចំនួននិងទាន់ពេលវេលារបស់សមភាគីតាមកិច្ចសន្យា។

- **ហួសកាលកំណត់សង (Past due)** សំដៅដល់ការខកខានរបស់សមភាគី ក្នុងការទូទាត់សងហិរញ្ញប្បទានឥណទានបានរយៈពេលមួយថ្ងៃ ឬ លើសនៃថ្ងៃកំណត់តាមកិច្ចសន្យា។

**ប្រការ ៥.-**

ការចាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនហិរញ្ញប្បទានដែលមានអ៊ីមភែរមិន គឺជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យទូទៅដែលគ្រឹះស្ថានត្រូវអនុវត្ត។ ដើម្បីគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រសិទ្ធភាព គ្រឹះស្ថានត្រូវមាន៖

១. ប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដែលមានលក្ខណៈសមស្របទៅនឹង ចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃសកម្មភាពអាជីវកម្ម

២. ការពិនិត្យឡើងវិញជាប្រចាំ ទៅលើប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដោយផ្អែកលើការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច សកម្មភាព អតិថិជន និងហានិភ័យនានា

៣. ប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពសម្រាប់ការកំណត់ជាមុន ការតាមដាន និងការវាស់វែងហានិភ័យឥណទានឲ្យបានត្រឹមត្រូវ រួមទាំងការកំណត់ឲ្យបានពេញលេញ និងការរាយការណ៍អំពីហិរញ្ញប្បទានដែលមានអ៊ីមភែរមិន និងការព្យាករណ៍ការខាតបង់នៃសំពៀតឥណទាន

៤. សំវិធានធនគ្រប់គ្រាន់សម្រាប់ហិរញ្ញប្បទានដែលមានអ៊ីមភែរមិន ស្របតាមស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា និង

៥. គោលនយោបាយ នីតិវិធី និងដំណើរការអនុវត្ត អនុលោមតាមលក្ខខណ្ឌតម្រូវទាំងអស់នៃប្រកាសនេះ។

## ជំពូកទី ២
## ការតាមដានហានិភ័យឥណទាន

**ប្រការ ៦.-**

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន ត្រូវទទួលខុសត្រូវក្នុងការធានាថា ការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងការកំណត់សំវិធានធន ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឲ្យមានសំវិធានធនសម្រាប់ហិរញ្ញប្បទានដែលមានអ៊ីមភែរមិន ក្នុងកម្រិតមួយសមស្រប និងគ្រប់គ្រាន់។ ក្រុមប្រឹក្សាភិបាលក៏ត្រូវធានាលើការអនុវត្តចំពោះ ការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងដំណើរការឲ្យស្របតាម ចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃសកម្មភាពរបស់គ្រឹះស្ថាន។

**ប្រការ ៧.-**

ក្រុមប្រឹក្សាភិបាល ត្រូវអនុម័តក្របខ័ណ្ឌ និងគោលនយោបាយសម្រាប់ការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងការកំណត់សំវិធានធន ព្រមទាំងគោលនយោបាយនៃការលុបចោលហិរញ្ញប្បទាន។ គោលនយោបាយនេះ ក៏ត្រូវកំណត់យន្តការតាមដាននិងរាយការណ៍ អំពីវិធានការប្រមូលមកវិញដែលគ្រឹះស្ថានត្រូវអនុវត្ត។

**ប្រការ ៨.-**

ក្រុមប្រឹក្សាភិបាលត្រូវធានាថា៖

១. នីតិវិធីនិងដំណើរការ អាចឲ្យគ្រឹះស្ថានកំណត់ឲ្យបានជាមុននូវការធ្វើចំណាត់ថ្នាក់ ការវាយតម្លៃ និងការដោះស្រាយបញ្ហាគុណភាពឥណទាន

២. ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ ទទួលបានព័ត៌មានគ្រប់គ្រាន់អំពីគុណភាពឥណទាន និងសំវិធានធនដែលពាក់ព័ន្ធទៅនឹងឥណទានឲ្យបានទៀងទាត់និងតាមពេលកំណត់

៣. ការវិនិច្ឆ័យលើមុខងារត្រួតពិនិត្យឡើងវិញនិងគ្រប់គ្រង ធ្វើឡើងស្របតាមគោលនយោបាយ និងនីតិវិធីរបស់គ្រឹះស្ថាន និង

៤. ការត្រួតពិនិត្យផ្ទៃក្នុងលើការវាយតម្លៃហានិភ័យឥណទាន និងដំណើរការធ្វើសំវិធានធន ធ្វើឡើងឲ្យបានត្រឹមត្រូវនិងទៀងទាត់ ដោយបុគ្គលដែលមានឯករាជ្យភាពពីប្រតិបត្តិការឥណទានរបស់គ្រឹះស្ថាន។

**ប្រការ ៩**.-

ក្រុមប្រឹក្សាភិបាល ត្រូវពិនិត្យឡើងវិញលើគោលនយោបាយនិងនីតិវិធី យ៉ាងតិចមួយឆ្នាំម្តង ដើម្បីធានាថា គោលនយោបាយនិងនីតិវិធីទាំងនេះនៅតែមានសង្គតិភាពជាមួយនឹងសកម្មភាព ស្ថានភាពសេដ្ឋកិច្ច អតិថិជន និងហានិភ័យឥណទានរបស់គ្រឹះស្ថាន។

**ប្រការ ១០**.-

ក្រុមប្រឹក្សាភិបាលត្រូវធានាថា គោលនយោបាយនិងនីតិវិធីសម្រាប់កំណត់សំវិធានធនលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ចំពោះហ្វាស៊ីលីធីទោល និងហ្វាស៊ីលីធីក្រុម ព្រមទាំងគោលនយោបាយនៃការលុបចោលហ្វាស៊ីលីធី ត្រូវតែបានអនុវត្តតាមឲ្យបានទាន់ពេលវេលា និងសមស្របទៅនឹងសកម្មភាព និងទម្រង់ហានិភ័យឥណទានរបស់គ្រឹះស្ថាន។

**ប្រការ ១១**.-

គណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវទទួលខុសត្រូវក្នុងការរៀបចំ និងការអនុវត្តឲ្យមានប្រសិទ្ធភាពនូវគោលនយោបាយនិងនីតិវិធីនានាដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ទាក់ទងនឹងការវាយតម្លៃឥណទាន ការធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងការលុបចោលហ្វាស៊ីលីធី។ គណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវធានាថា៖

១. បុគ្គលិកពាក់ព័ន្ធ ត្រូវយល់ដឹងឲ្យបានច្បាស់លាស់ និងអនុវត្តដោយសង្គតិភាពនូវគោលនយោបាយផ្ទៃក្នុង នីតិវិធី និងដំណើរការត្រួតពិនិត្យឥណទានឡើងវិញនិងការធ្វើសំវិធានធន

២. ដំណើរការធ្វើសំវិធានធនលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ត្រូវអនុវត្តឲ្យបានសមស្រប មានលក្ខណៈជាប្រព័ន្ធនិងមានសង្គតិភាព ដើម្បីជួយសម្រួលដល់ការប្រមូលឲ្យបានទាន់ពេលវេលានូវព័ត៌មានបន្ថែម ឬថ្មីៗ ទាក់ទងទៅនឹងលទ្ធភាពប្រមូលមកវិញនៃហ្វាស៊ីលីធី ក្នុងគោលបំណងកំណត់សំវិធានធនទៅលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិននោះ។ យ៉ាងហោចណាស់ ដំណើរការនេះត្រូវផ្តល់ព័ត៌មានសមស្រប និងទាន់ពេលវេលាអំពី៖

ក. ហ្វាស៊ីលីធីដែលហួសកាលកំណត់សង

ខ. ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន

គ. តម្លៃជាក់ស្តែងរបស់ទ្រព្យធានាលើហ្វាស៊ីលីធី

ឃ. ប្រភពផ្សេងទៀតនៃលំហូរសាច់ប្រាក់ ដែលគ្រឹះស្ថានអាចប្រើជាមូលដ្ឋានក្នុងការកំណត់កម្រិតនៃអ៊ីមភែរមិន និងទំហំនៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និង

ង. ទំហំសំវិធានធនចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនដែលត្រូវកត់ត្រា។

៣. ការតាមដាននិងការត្រួតពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ននិងត្រឹមត្រូវ ត្រូវបានអនុវត្តចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ការធ្វើសំវិធានធន និងការប្រមូលមកវិញចំពោះហ្វាស៊ីលីធីដែលបានលុបចោល។



8/8

## ជំពូកទី ៣
## ការចាត់ថ្នាក់ហានិភ័យឥណទាន

**ប្រការ ១២**.-

ប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទានដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ត្រូវរួមបញ្ចូលប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទានដែលបានកំណត់ច្បាស់លាស់ ដោយត្រូវកំណត់ការទទួលខុសត្រូវលម្អិតរបស់បុគ្គលពាក់ព័ន្ធនៅក្នុងគ្រឹះស្ថាន។

**ប្រការ ១៣**.-

គ្រឹះស្ថានត្រូវរៀបចំដំណើរការចាត់ថ្នាក់ហ្វាស៊ីលីធីឲ្យមានលក្ខណៈជាប្រព័ន្ធ និងមានសង្គតិភាពដោយផ្អែកលើមូលដ្ឋានហានិភ័យឥណទាន។ ក្នុងគោលបំណងនេះ គ្រឹះស្ថានត្រូវមានប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទាន ដែលសមស្របទៅនឹងកម្រិតហានិភ័យពាក់ព័ន្ធនឹង ចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃហ្វាស៊ីលីធីរបស់គ្រឹះស្ថាន។ ហ្វាស៊ីលីធីធំៗនឹងត្រូវធ្វើចំណាត់ថ្នាក់ដោយផ្អែកតាមវិធីសាស្ត្រវាយតម្លៃហានិភ័យឥណទានដែលមានលក្ខណៈពិស្តារ ចំណែកឯហ្វាស៊ីលីធីតូចៗដែលមានចរិតលក្ខណៈប្រហាក់ប្រហែលគ្នានិងស្ថិតក្រោមការគ្រប់គ្រងសំពៀតតែមួយ អាចត្រូវបានចាត់ថ្នាក់ដោយផ្អែកតាមវិធីសាស្ត្រចាត់ថ្នាក់ឥណទាននេះ ឬអាចចាត់ថ្នាក់តាមប្រវត្តិហ្វាស៊ីលីធីខាតបង់។ ការចាត់ថ្នាក់ហានិភ័យឥណទានប្រកបដោយភាពជឿជាក់បាននឹងជួយក្នុងការវាយតម្លៃហ្វាស៊ីលីធីដោយប្រុងប្រយ័ត្ន និងកំណត់ការធ្វើសំវិធានធនគ្រប់គ្រាន់ចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ៤៨ ដល់ ប្រការ ៥២ នៃប្រកាសនេះ។

**ប្រការ ១៤**.-

គ្រឹះស្ថានត្រូវរក្សាទុកសំណុំឯកសារឥណទានរបស់សមភាគីទាំងអស់ជារូបវន្ត និង/ឬ អេឡិកត្រូនិកដែលត្រូវមានព័ត៌មានគ្រប់គ្រាន់និងទាន់ពេលវេលាអំពីលទ្ធភាពសងបំណុលរបស់សមភាគីដើម្បី៖

១. សម្រួលដល់ការតាមដាន និងការត្រួតពិនិត្យឡើងវិញចំពោះហ្វាស៊ីលីធីទាំងអស់របស់គ្រឹះស្ថានឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាព និង

២. សម្រួលដល់សវនករផ្ទៃក្នុងនិងក្រុមហ៊ុនសវនកម្មឲ្យទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ការផ្តល់មតិយោបល់ច្បាស់លាស់និងដោយសត្យានុម័ត ទៅលើគុណភាពហ្វាស៊ីលីធីទាំងអស់ក្នុងសំពៀតឥណទាន។

**ប្រការ ១៥**.-

គ្រឹះស្ថានត្រូវអនុវត្តការពិនិត្យឡើងវិញឲ្យមានលក្ខណៈជាប្រព័ន្ធនិងទៀងទាត់ចំពោះហ្វាស៊ីលីធីទាំងអស់ ទោះបីជាមាន ឬមិនមានអ៊ីមភែរមិន រួមបញ្ចូលទាំងខ្ទង់ក្រៅតារាងតុល្យការ ដើម្បីឲ្យការចាត់ថ្នាក់ហ្វាស៊ីលីធីអាចធ្វើទៅបានទាន់ពេលវេលា។ គ្រឹះស្ថានត្រូវកំណត់វដ្តនៃការពិនិត្យឡើងវិញទៅតាមប្រភេទផ្សេងៗគ្នានៃហ្វាស៊ីលីធី។ ការពិនិត្យឡើងវិញចំពោះហ្វាស៊ីលីធីជាលក្ខណៈទោល និងហ្វាស៊ីលីធីដែលមានហានិភ័យខ្ពស់ ត្រូវមានវដ្តនៃការពិនិត្យឡើងវិញញឹកញាប់។ វដ្តនៃការពិនិត្យឡើងវិញនេះមិនត្រូវមានរយៈពេលលើសពីមួយឆ្នាំទេ។

**ប្រការ ១៦**.-

ការចាត់ថ្នាក់ហានិភ័យឥណទាន ត្រូវបានធ្វើឡើងឲ្យបានលម្អិត ច្បាស់លាស់ និងគ្រប់គ្រាន់ទៅតាមកម្រិតនៃហានិភ័យឥណទានរបស់គ្រឹះស្ថាន។ គ្រឹះស្ថានត្រូវបែងចែកហ្វាស៊ីលីធីតាមប្រភេទ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃលើសមត្ថភាពទូទាត់សងរបស់សមភាគីតាមរយៈប្រភពចំណូលជាក់ស្តែង។

លក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃសមត្ថភាពទូទាត់សងរបស់សមភាគី ត្រូវមានចំណុចយ៉ាងតិចដូចខាងក្រោម៖

១. ប្រវត្តិទូទាត់សង

២. ស្ថានភាពហិរញ្ញវត្ថុរបស់សមភាគីនាពេលបច្ចុប្បន្ន និងការព្យាករណ៍

៣. ចក្ខុវិស័យអាជីវកម្ម និងការព្យាករណ៍លំហូរសាច់ប្រាក់ ដោយផ្អែកលើការសន្មតដែលមានលក្ខណៈជាក់ស្តែងនិងប្រុងប្រយ័ត្ន

៤. លទ្ធភាពនិងឆន្ទៈទូទាត់សង

៥. ស្ថានភាពសេដ្ឋកិច្ច និង

៦. គុណភាពនៃសំណុំឯកសារ។

ដូចមានចែងក្នុងប្រការ ១៣ នៃប្រកាសនេះ ហ្វាស៊ីលីធីដែលមានចរិតលក្ខណៈហានិភ័យប្រហាក់ប្រហែលគ្នា និងស្ថិតក្រោមកម្រិតកំណត់ជាសារវន្ត (Materiality Threshold) អាចត្រូវចាត់ថ្នាក់ក្នុងសំពៀតឥណទានតែមួយ។

ហេតុការណ៍ណាមួយដែលនាំឲ្យប៉ះពាល់ដល់ប្រភពចំណូលចម្បងក្នុងការទូទាត់សង អាចនាំឲ្យមានការចាត់ថ្នាក់ឥណទានទាបជាងមុន ទោះបីជាហ្វាស៊ីលីធីនោះស្ថិតក្នុងចំណាត់ថ្នាក់ល្អ ឬត្រូវបានការពារដោយទ្រព្យធានាក៏ដោយ។ ការចាត់ថ្នាក់ឡើងវិញក៏អាចត្រូវបានធ្វើឡើង ប្រសិនបើសមភាគីមិនអាចបំពេញតាមលក្ខខណ្ឌនៃកិច្ចសន្យា និងបានកែប្រែលក្ខខណ្ឌនៃកិច្ចសន្យា ធ្វើបុនហិរញ្ញប្បទាន ឬទទួលបុរេប្រទានបន្ថែម។

ក្នុងករណីដែលអាចមានការចាត់ថ្នាក់ខុសគ្នាដោយផ្អែកលើកត្តាអត្តនោម័តិ គ្រឹះស្ថានត្រូវជ្រើសយកការចាត់ថ្នាក់ទាបជាងគេ។ ជាងនេះទៅទៀត រាល់លក្ខខណ្ឌដែលមានចែងអំពីការចាត់ថ្នាក់ឥណទានក្នុងបញ្ញត្តិនៃប្រការ ១៧ និងប្រការ ១៨ នៃប្រកាសនេះ មិនអាចរារាំងពីការចាត់ថ្នាក់ទាបជាងមុននោះទេ នៅពេលដែលការវិភាគទៅលើស្ថានភាពហិរញ្ញវត្ថុ លទ្ធភាពសង និងឆន្ទៈក្នុងការសងរបស់សមភាគី អាចបង្ហាញថាឥណទាននោះអាចត្រូវបានចាត់ថ្នាក់ទាបជាងមុន។

**ប្រការ ១៧**.-

ស្តង់ដារនៃការចាត់ថ្នាក់ហ្វាស៊ីលីធីអាចមានរូបភាពផ្សេងៗគ្នានៅក្នុងគ្រឹះស្ថាន ប៉ុន្តែយន្តការនៃការចាត់ថ្នាក់របស់គ្រឹះស្ថាននីមួយៗត្រូវមានលក្ខណៈលម្អិតគ្រប់គ្រាន់ក្នុងការតាមដានការវិវត្តនៃហានិភ័យ។ គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីយ៉ាងហោចប្រាំប្រភេទ។ លើកលែងតែមានការចែងផ្សេងទៀតក្នុង ប្រការ ១៨ នៃប្រកាសនេះ ការចាត់ថ្នាក់ទាំងប្រាំប្រភេទនេះ មានដូចខាងក្រោម៖

**១. ចំពោះហ្វាស៊ីលីធីដែលមានកាលកំណត់ដំបូងលើសពីមួយឆ្នាំ៖**

ក. **ធម្មតា៖** ហ្វាស៊ីលីធីមានការទូទាត់សងតាមកាលកំណត់ និងមិនមានការសង្ស័យលើការទូទាត់សងនាពេលអនាគត។ ការទូទាត់សងត្រូវបានធ្វើឡើងទៀងទាត់ស្របតាមកិច្ចសន្យា ហើយហ្វាស៊ីលីធីមិនមានបង្ហាញពីសញ្ញាចុះខ្សោយទាក់ទងនឹងសមត្ថភាពទូទាត់សង អាជីវកម្ម លំហូរសាច់ប្រាក់ និងស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី។

ខ. **ឃ្លាំមើល៖** ហ្វាស៊ីលីធីប្រភេទនេះកំពុងស្ថិតនៅក្រោមកិច្ចគាំពារ និងមិនទាន់ហួសកាលកំណត់ទូទាត់សង ប៉ុន្តែបង្ហាញពីសញ្ញាចុះខ្សោយដែលអាចជះឥទ្ធិពលដល់ការទូទាត់សងរបស់សមភាគីនាពេលអនាគត ប្រសិនបើមិនមានវិធានការកែតម្រូវទាន់ពេលវេលា និងការយកចិត្តទុកដាក់ឲ្យបានដិតដល់ពីគ្រឹះស្ថាន។ សញ្ញាចុះខ្សោយនេះ មានដូចជា ស្ថានភាពធ្លាក់ចុះជាបណ្តើរៗនៃអាជីវកម្ម ឬស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី និងការធ្លាក់ចុះនៃ

ស្ថានភាពសេដ្ឋកិច្ចនិងទីផ្សារ ដែលអាចប៉ះពាល់ដល់លទ្ធភាពរកប្រាក់ចំណេញ និងសមត្ថភាពទូទាត់សងនាពេលអនាគត ឬការធ្លាក់ចុះតម្លៃទ្រព្យធានា។ ចំណាត់ថ្នាក់នេះត្រូវធ្វើឡើងដោយមានហេតុផលច្បាស់លាស់ និងមិនគួរប្រើប្រាស់ជាការសម្របសម្រួលនៅពេលចាត់ថ្នាក់រវាងហ្វាស៊ីលីធីធម្មតា និងហ្វាស៊ីលីធីក្រោមស្តង់ដារទេ។

ហ្វាស៊ីលីធីណាដែលហួសកាលកំណត់សងរយៈពេល ៣០ ថ្ងៃ ឬលើសពីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "ឃ្លាំមើល"។

ក្នុងករណី ការទូទាត់ការប្រាក់ក្នុងរយៈពេលពី ៣០ ថ្ងៃ ទៅ ៨៩ ថ្ងៃ ត្រូវបញ្ចូលទៅជាប្រាក់ដើមធ្វើបុនហិរញ្ញប្បទាន ឬបង្វិលទៅជាហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះនឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "ឃ្លាំមើល" ឬអន់ជាងនេះ។

គ. **ក្រោមស្តង់ដារ៖** ហ្វាស៊ីលីធីប្រភេទនេះ បង្ហាញភាពទន់ខ្សោយគួរឲ្យកត់សម្គាល់ និងមិនត្រូវបានគាំពារគ្រប់គ្រាន់ដោយស្ថានភាពអាជីវកម្ម ឬហិរញ្ញវត្ថុបច្ចុប្បន្ន និងសមត្ថភាពទូទាត់សងរបស់សមភាគី។ ជាពិសេស ប្រភពចំណូលចម្បងមិនគ្រប់គ្រាន់សម្រាប់ទូទាត់សងបំណុលដោយមិនគិតពីប្រភពចំណូលបន្ទាប់បន្សំផ្សេងៗទៀត ដូចជាការលក់ទ្រព្យធានាជាដើម។ កត្តានាំឲ្យមានការចាត់ថ្នាក់ក្រោមស្តង់ដារ មានដូចជា៖

- សមភាគីគ្មានលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចសងប្រាក់តាមកិច្ចសន្យា
- ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារមិនអំណោយផល ដែលនឹងជះឥទ្ធិពលមិនល្អដល់អាជីវកម្ម និងលទ្ធភាពរកប្រាក់ចំណេញរបស់សមភាគីនាពេលអនាគត
- ស្ថានភាពហិរញ្ញវត្ថុធ្លាក់ចុះ និង/ឬ សមភាគីគ្មានលទ្ធភាពក្នុងការស្វែងរកចំណូលគ្រប់គ្រាន់ដើម្បីទូទាត់សងបំណុល
- សមភាគីជួបប្រទះការលំបាកក្នុងការទូទាត់ហ្វាស៊ីលីធីផ្សេងៗទៀតរបស់គ្រឹះស្ថានផ្ទាល់ ឬរបស់គ្រឹះស្ថានផ្សេងទៀត ប្រសិនបើមានព័ត៌មានគ្រប់គ្រាន់ និង
- សមភាគីល្មើសលើលក្ខខណ្ឌនៃកិច្ចសន្យាហិរញ្ញវត្ថុ។

ហ្វាស៊ីលីធីដែលហួសកាលកំណត់សងចំនួន ៩០ ថ្ងៃ ឬ លើសពីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "ក្រោមស្តង់ដារ"។

ក្នុងករណី ការទូទាត់ការប្រាក់ក្នុងរយៈពេលពី ៩០ ថ្ងៃ ទៅ ១៧៩ ថ្ងៃ ត្រូវបញ្ចូលទៅជាប្រាក់ដើមធ្វើបុនហិរញ្ញប្បទាន ឬបង្វិលទៅជាហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះនឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "ក្រោមស្តង់ដារ" ឬអន់ជាងនេះ។

ឃ. **សង្ស័យ៖** ហ្វាស៊ីលីធីប្រភេទនេះ បង្ហាញភាពទន់ខ្សោយធ្ងន់ធ្ងរ ជាងចំណាត់ថ្នាក់ "ក្រោមស្តង់ដារ" ដោយសារមានភាពសង្ស័យខ្លាំង ឬមិនមានភាពច្បាស់លាស់ ចំពោះការប្រមូលមកវិញនូវហ្វាស៊ីលីធីទាំងអស់ ផ្អែកលើគថភាពជាក់ស្តែង លក្ខខណ្ឌ ឬតម្លៃទ្រព្យធានា។ ការខាតបង់នាពេលអនាគតមានកម្រិតខ្ពស់ ទោះបីចំនួនជាក់លាក់នៃការបាត់បង់មិនទាន់អាចកំណត់បានក៏ដោយ។

ហ្វាស៊ីលីធីដែលហួសកាលកំណត់សងចំនួន ១៨០ ថ្ងៃ ឬលើសពីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "សង្ស័យ"។

ក្នុងករណី ការទូទាត់ការប្រាក់ក្នុងរយៈពេលពី ១៨០ ថ្ងៃ ទៅ ៣៥៩ ថ្ងៃ ត្រូវបញ្ចូលទៅជាប្រាក់ដើមធ្វើបុនហិរញ្ញប្បទាន ឬបង្វិលទៅជាហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះនឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "សង្ស័យ" ឬអន់ជាងនេះ។

ង. **បាត់បង់៖** ហ្វាស៊ីលីធីប្រភេទនេះ ត្រូវបានចាត់ថ្នាក់ជាហ្វាស៊ីលីធី "បាត់បង់" នៅពេលគ្រឹះស្ថានមិនអាចប្រមូលមកវិញបាន ហើយគ្រឹះស្ថានក៏គ្មាន ឬមានមធ្យោបាយតិចតួចក្នុងការប្រមូលមកវិញនូវសមតុល្យហ្វាស៊ីលីធីដក់សល់ ពីសមភាគី។

ហ្វាស៊ីលីធីដែលហួសកាលកំណត់សងចំនួន ៣៦០ ថ្ងៃ ឬលើសពីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "បាត់បង់"។

ក្នុងករណី ការទូទាត់ការប្រាក់ក្នុងរយៈពេលពី ៣៦០ ថ្ងៃ ឬច្រើនជាង ត្រូវបញ្ចូលទៅជាប្រាក់ដើមធ្វើបុនហិរញ្ញប្បទាន ឬបង្វិលទៅជាហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះ នឹងត្រូវចាត់ថ្នាក់ជាហ្វាស៊ីលីធី "បាត់បង់"។

**២. ចំពោះហ្វាស៊ីលីធីដែលមានកាលកំណត់ដំបូងតិចជាង ឬស្មើមួយឆ្នាំ៖**

ចំពោះហ្វាស៊ីលីធី ដែលមានកាលកំណត់ដំបូងរយៈពេលតិចជាង ឬស្មើមួយឆ្នាំ គឺជាហ្វាស៊ីលីធីរយៈពេលខ្លី។ ការកំណត់ចំនួនថ្ងៃអតិបរមានៅក្នុងចំណាត់ថ្នាក់នីមួយៗខាងលើត្រូវបានបន្ថយដូចខាងក្រោម៖

ក. "ធម្មតា" មានការទូទាត់សងតាមកាលកំណត់

ខ. "ឃ្លាំមើល" បើហួសកាលកំណត់សងអតិបរមារយៈពេល ៣០ ថ្ងៃ

គ. "ក្រោមស្តង់ដារ" បើហួសកាលកំណត់សងអតិបរមារយៈពេល ៦០ ថ្ងៃ

ឃ. "សង្ស័យ" បើហួសកាលកំណត់សងអតិបរមារយៈពេល ៩០ ថ្ងៃ

ង. "បាត់បង់" បើហួសកាលកំណត់សងអតិបរមារយៈពេល ១៨០ ថ្ងៃ។

ឥណទានវិបារូបន៍ដោយមិនគិតពីឥណប្រតិទាន ត្រូវចាត់ជាឥណទានរយៈពេលខ្លី និងត្រូវបានប្រើប្រាស់សម្រាប់តែហិរញ្ញប្បទានរយៈពេលខ្លីប៉ុណ្ណោះ។ ឥណទានវិបារូបន៍នឹងត្រូវចាត់ថ្នាក់ផ្សេងៗគ្នាតាមលំដាប់ដូចការកំណត់ក្នុងចំណុចទី២ នៃប្រការនេះ អាស្រ័យលើ ១). ឥណទានវិបារូបន៍ត្រូវបានប្រើលើសកម្រិតអនុម័ត ២). គណនីឥណទានវិបារូបន៍មិនមានចលនាសាច់ប្រាក់ចេញចូល ឬ ៣). លំហូរចូលសាច់ប្រាក់សុទ្ធក្នុងគណនីនោះមិនមានភាពគ្រប់គ្រាន់ដើម្បីទូទាត់ការប្រាក់។ គ្រឹះស្ថានត្រូវកែប្រែលក្ខណៈដើមនៃឥណទានវិបារូបន៍ដែលមិនមានលំហូរចូលសាច់ប្រាក់សុទ្ធសម្រាប់ក្នុងអំឡុងពេល ៦០ ថ្ងៃ ឲ្យទៅជាឥណទានមានកាលកំណត់។

ចំនួនថ្ងៃដែលហួសកាលកំណត់ខាងលើនៃប្រការនេះ ត្រូវចាត់ជាចំនួនថ្ងៃអតិបរមាប៉ុណ្ណោះ។ ការកំណត់ខាងលើនេះនឹងមិនហាមឃាត់គ្រឹះស្ថានក្នុងការចាត់ថ្នាក់អន់ជាងមុន នៅពេលដែលគ្រឹះស្ថានគិតថាសមស្រប។

**ប្រការ ១៨.-**

ចំពោះហ្វាស៊ីលីធីដែលត្រូវទូទាត់សងប្រចាំត្រីមាស ឆមាស ឬរយៈពេលវែងជាងនេះ ហើយសមភាគីខកខានក្នុងការទូទាត់សង គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីនោះ "ក្រោមស្តង់ដារ" ឬចាត់ថ្នាក់អន់ជាងនេះផ្អែកលើស្ថានភាពរបស់សមភាគី លើកលែងតែគ្រឹះស្ថានអាចបញ្ជាក់ថាហ្វាស៊ីលីធីមិនមានសញ្ញាទន់ខ្សោយ។ សម្រាប់គោលបំណងនៃប្រការ ១៨ នៃប្រកាសនេះ ការខកខានទូទាត់សងត្រូវគិតចាប់ពី ០៥ ថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទូទាត់សង។ គ្រឹះស្ថានអាចចាត់ថ្នាក់ហ្វាស៊ីលីធី "ក្រោមស្តង់ដារ" ក្នុងករណីតែសមភាគីអាចបង្ហាញច្បាស់ថា ការខកខានសងនេះគ្រាន់តែជាការយឺតយ៉ាវបណ្តោះអាសន្ន។

**ប្រការ ១៩.-**

ហ្វាស៊ីលីធីដែលត្រូវបានចាត់ថ្នាក់ "ក្រោមស្តង់ដារ" "សង្ស័យ" និង "បាត់បង់" នឹងត្រូវចាត់ថ្នាក់ជា "ហ្វាស៊ីលីធីមិនដំណើរការ" (Non-performing Facilities)។ ចំណែកឯហ្វាស៊ីលីធី "ធម្មតា" និង "ឃ្លាំមើល" នឹងត្រូវចាត់ថ្នាក់ជា "ហ្វាស៊ីលីធីដំណើរការ" (Performing Facilities)។

**ប្រការ ២០.-**

កម្រិតលម្អិតនៃការចាត់ថ្នាក់ហានិភ័យឥណទាន នឹងសម្រួលដល់ការកំណត់ឲ្យបានត្រឹមត្រូវចំពោះចរិតលក្ខណៈនៃសំពៀតឥណទាន ការរាយការណ៍ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធន។

**ប្រការ ២១.-**

ហ្វាស៊ីលីធីហួសកាលកំណត់សង ត្រូវបានចាត់ទុកថាមានហានិភ័យខកខានសងខ្ពស់ជាងហ្វាស៊ីលីធីដែលបានទូទាត់សងទៅតាមកិច្ចសន្យា។ គ្រឹះស្ថានត្រូវមានប្រព័ន្ធតាមដានសមស្របក្នុងការគ្រប់គ្រងហ្វាស៊ីលីធីហួសកាលកំណត់សងឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកាត់បន្ថយជាអប្បបរមានូវការប្រែក្លាយជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។ គ្រឹះស្ថានត្រូវមាននីតិវិធីនិងដំណើរការដើម្បីកំណត់ តាមដាន និងរាយការណ៍ដល់ក្រុមប្រឹក្សាភិបាល នូវស្ថានភាពរបស់ហ្វាស៊ីលីធីហួសកាលកំណត់សង រួមទាំងហ្វាស៊ីលីធីដែលមិនទាន់បានចាត់ថ្នាក់ថាមានអ៊ីមភែរមិន។

**ប្រការ ២២.-**

គ្រឹះស្ថានត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មការចាត់ថ្នាក់ហានិភ័យឥណទានចំពោះហ្វាស៊ីលីធីនៅពេលដែលគ្រឹះស្ថានទទួលបានព័ត៌មានថ្មីដែលពាក់ព័ន្ធនឹងការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធីនោះ។ លើសពីនេះ គ្រឹះស្ថានត្រូវពិនិត្យឡើងវិញប្រចាំគ្រា និងមានឯកសារបញ្ជាក់ច្បាស់លាស់ចំពោះហ្វាស៊ីលីធីទាំងអស់ ដើម្បីធ្វើបច្ចុប្បន្នកម្មចំណាត់ថ្នាក់។ រាល់ចំណាត់ថ្នាក់ហានិភ័យឥណទានត្រូវវាយតម្លៃឡើងវិញយ៉ាងតិចម្តងក្នុងមួយឆ្នាំ។ គ្រឹះស្ថានត្រូវពិនិត្យឡើងវិញចំពោះហ្វាស៊ីលីធីធំ ឬមានហានិភ័យខ្ពស់ ឬ "ក្រោមស្តង់ដារ" ឬអន់ជាងនេះឲ្យបានញឹកញាប់ យ៉ាងតិចម្តងក្នុងមួយឆមាស ឬកាន់តែញឹកញាប់ជាងនេះសម្រាប់ហ្វាស៊ីលីធីដែលជួបនឹងការធ្លាក់ចុះលទ្ធភាពសងប្រាក់វិញ។

## ជំពូកទី ៤
## ហ្វាស៊ីលីធីរៀបចំឡើងវិញ

**ប្រការ ២៣.-**

"ហ្វាស៊ីលីធីរៀបចំឡើងវិញ" (Restructured Facilities) ជាហ្វាស៊ីលីធីដែលមានលក្ខខណ្ឌនៃកិច្ចសន្យាដើមត្រូវបានកែប្រែដើម្បីផ្តល់ការអនុគ្រោះដល់សមភាគី ដែលមានស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន។ ការអនុគ្រោះដែលត្រូវចាត់ទុកថាជា "ហ្វាស៊ីលីធីរៀបចំឡើងវិញ" មានដូចខាងក្រោមៈ

១. ការកាត់បន្ថយចំនួនប្រាក់ដើមហ្វាស៊ីលីធី ឬចំនួនដែលត្រូវសងនៅឥណប្រតិទាន
២. ការបន្ថយអត្រាការប្រាក់ទាបជាងលក្ខខណ្ឌនៃកិច្ចសន្យាដើម
៣. ការពន្យារពេលទូទាត់សងប្រាក់ដើម ឬការប្រាក់ ឬការធ្វើមូលធនកម្មការប្រាក់
៤. ការពន្យារឥណប្រតិទាន ឬ
៥. ការបន្ថែម និង/ឬការផ្លាស់ប្តូរអ្នករួមខ្ចី និង/ឬអ្នកធានា ប្រសិនបើមាន។

**ប្រការ ២៤.-**

ចំពោះហ្វាស៊ីលីធីដែលត្រូវបានចាត់ទុកជា "ហ្វាស៊ីលីធីរៀបចំឡើងវិញ" គ្រឹះស្ថាននិងសមភាគីត្រូវយល់ព្រមជាផ្លូវការលើលក្ខខណ្ឌថ្មីនៃកិច្ចសន្យា។ ក្នុងករណីដែលលក្ខខណ្ឌថ្មីនៃកិច្ចសន្យាមិនបានធ្វើឡើងជាផ្លូវការ ហ្វាស៊ីលីធីនោះមិនមែនជាហ្វាស៊ីលីធីរៀបចំឡើងវិញទេ និងត្រូវបានចាត់ទុកថាជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។

**ប្រការ ២៥**.-

ប្រសិនបើគ្រឹះស្ថានមិនមានព័ត៌មានគ្រប់គ្រាន់អំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់សមភាគី ហ្វាស៊ីលីធីដែលអាចទទួលបានការអនុគ្រោះណាមួយដូចមានចែងក្នុងប្រការ ២៣ ខាងលើ ត្រូវបានចាត់ទុកថាជា ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។

**ប្រការ ២៦**.-

គ្រឹះស្ថានត្រូវមានគោលនយោបាយនិងនីតិវិធីជាលាយលក្ខណ៍អក្សរដែលអនុម័តដោយក្រុមប្រឹក្សាភិបាល សម្រាប់កំណត់អំពីស្ថានភាព និងលក្ខខណ្ឌនៃហ្វាស៊ីលីធីដែលត្រូវបានចាត់ទុកជា "ហ្វាស៊ីលីធីរៀបចំឡើងវិញ" និងសម្រាប់តាមដាននិងគ្រប់គ្រងហ្វាស៊ីលីធីរៀបចំឡើងវិញ។ រាល់ការរៀបចំហ្វាស៊ីលីធីឡើងវិញត្រូវមានឯកសារវាយតម្លៃឥណទានត្រឹមត្រូវគ្រប់គ្រាន់ និងមានសម្មតិកម្មជាក់លាក់អំពីការទូទាត់សងទាំងស្រុងស្របតាមលក្ខខណ្ឌថ្មីនៃកិច្ចសន្យា។

**ប្រការ ២៧**.-

ហ្វាស៊ីលីធីរៀបចំឡើងវិញ អាចធ្វើបានតែចំពោះសមភាគីណាដែលស្ថានភាពអាជីវកម្ម និង/ឬស្ថានភាពហិរញ្ញវត្ថុនៅតែមានចីរភាព ហើយគ្រឹះស្ថានរំពឹងថាសមភាគីជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ និងការទូទាត់សងតែក្នុងរយៈពេលបណ្ដោះអាសន្នប៉ុណ្ណោះ។ គ្រឹះស្ថានត្រូវពន្យល់អំពីការសម្រេចក្នុងការរៀបចំហ្វាស៊ីលីធីឡើងវិញផ្អែកតាមប្រការ ២៨ នៃប្រកាសនេះ នូវមូលហេតុដែលគ្រឹះស្ថានចាត់ទុកសមភាគីនោះស្ថិតក្នុងស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុនិងការទូទាត់សងក្នុងរយៈពេលបណ្ដោះអាសន្ន។ ការរៀបចំហ្វាស៊ីលីធីឡើងវិញមិនត្រូវប្រើប្រាស់ដើម្បីរួចផុតពី៖

១. ការទទួលស្គាល់ជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ៤៨ ដល់ប្រការ ៥២ នៃប្រកាសនេះ

២. ការបង្កើនសំវិធានធនចំពោះការខាតបង់ឥណទានដែលរំពឹងទុក និង

៣. ការបញ្ឈប់ពីការទទួលស្គាល់ចំណូលការប្រាក់ផ្អែកលើមូលដ្ឋានបង្គរ។

**ប្រការ ២៨**.-

គ្រឹះស្ថានត្រូវកំណត់លក្ខខណ្ឌថ្មីនៃហ្វាស៊ីលីធីរៀបចំឡើងវិញ ដោយផ្អែកលើសមត្ថភាពទូទាត់សងរបស់សមភាគីតាមរយៈការព្យាករណ៍លំហូរសាច់ប្រាក់ថ្មីដោយមានសម្មតិកម្មត្រឹមត្រូវ និងប្រុងប្រយ័ត្នចំពោះស្ថានភាពហិរញ្ញវត្ថុ និង/ឬ អាជីវកម្មរបស់សមភាគី។ រាល់ការសម្រេចរៀបចំហ្វាស៊ីលីធីឡើងវិញគ្រឹះស្ថានត្រូវមានហេតុផលត្រឹមត្រូវ ដោយមានការពន្យល់ឲ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ និងរក្សាទុកជាឯកសារ។

**ប្រការ ២៩**.-

ហ្វាស៊ីលីធីនីមួយៗ មិនអាចធ្វើការរៀបចំឡើងវិញលើសពីមួយដងឡើយ។ ប្រសិនបើមានការរៀបចំឡើងវិញលើសពីមួយដង ហ្វាស៊ីលីធីនោះត្រូវចាត់ថ្នាក់យ៉ាងហោចណាស់ជាហ្វាស៊ីលីធី "ក្រោមស្តង់ដារ" ។

**ប្រការ ៣០**.-

ក្នុងដំណើរការរៀបចំហ្វាស៊ីលីធីឡើងវិញ គ្រឹះស្ថានអាចអនុញ្ញាតឲ្យពន្យារពេលសងដោយមិនត្រូវលើសពីរយៈពេល ០៦ ខែឡើយ។ ការអនុញ្ញាតនេះត្រូវមានការវាយតម្លៃហានិភ័យឥណទានឲ្យបានហ្មត់ចត់និងត្រឹមត្រូវ។

**ប្រការ ៣១.-**

ការរៀបចំហ្វាស៊ីលីធីឡើងវិញ ត្រូវធ្វើឡើងដោយបុគ្គល ឬផ្នែកផ្សេងដែលមិនទទួលបន្ទុកក្នុងដំណើរការផ្តល់ឥណទាន។ ការអនុញ្ញាតឲ្យមានការរៀបចំហ្វាស៊ីលីធីឡើងវិញត្រូវធ្វើឡើងដោយគណៈគ្រប់គ្រងដែលមានសិទ្ធិសម្រេចសមស្រប និងយ៉ាងហោចណាស់ ត្រូវមានការចូលរួមចាប់ពីគណៈគ្រប់គ្រងជាន់ខ្ពស់ឡើងទៅ។

**ប្រការ ៣២.-**

របាយការណ៍ស្តីពីស្ថានភាពនៃហ្វាស៊ីលីធីរៀបចំឡើងវិញ ត្រូវផ្តល់ជូនគណៈគ្រប់គ្រងជាន់ខ្ពស់យ៉ាងតិចម្តងក្នុងមួយត្រីមាស ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តស្របតាមលក្ខខណ្ឌថ្មីនៃកិច្ចសន្យា និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យរួមរបស់គ្រឹះស្ថាន ព្រមទាំងចាត់វិធានការកែតម្រូវសមស្រប ក្នុងករណីមានចំណុចខ្វះចន្លោះ។

ក្នុងករណីហ្វាស៊ីលីធីរៀបចំឡើងវិញមានចំណុចខ្វះចន្លោះ របាយការណ៍ស្តីពីស្ថានភាពហ្វាស៊ីលីធីរៀបចំឡើងវិញនេះ ត្រូវបានផ្តល់ភ្លាមៗជូនគណៈគ្រប់គ្រងជាន់ខ្ពស់។

**ប្រការ ៣៣.-**

ក្រោយពីបញ្ចប់ដំណើរការរៀបចំហ្វាស៊ីលីធីឡើងវិញ ហ្វាស៊ីលីធីត្រូវបានរក្សាការចាត់ថ្នាក់ដដែលរហូតដល់ហ្វាស៊ីលីធីនោះអាចចាត់ថ្នាក់ល្អជាងមុន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងបញ្ញត្តិនៃប្រការ ៨១ និងប្រការ ៨២ នៃប្រកាសនេះ។

## ជំពូកទី ៥
## មុនហិរញ្ញប្បទាន

**ប្រការ ៣៤.-**

"មុនហិរញ្ញប្បទាន" សំដៅដល់ការអនុវត្ត ឬយន្តការទាំងឡាយណារបស់គ្រឹះស្ថាន ដែលអនុញ្ញាតឲ្យមានការជំនួសកាតព្វកិច្ចសងបំណុលដែលមានស្រាប់ ជាមួយនឹងកាតព្វកិច្ចសងបំណុលថ្មីក្នុងលក្ខខណ្ឌនៃកិច្ចសន្យាថ្មី។

**ប្រការ ៣៥.-**

"មុនហិរញ្ញប្បទាន" មិនត្រូវបានអនុវត្តដើម្បីប្រែក្លាយហ្វាស៊ីលីធីដែលមិនល្អ ទៅជា "ហ្វាស៊ីលីធីល្អជានិច្ច" ក្នុងគោលបំណងគេចវេសពីការធ្វើសំវិធានធន ឬលុបចោលហ្វាស៊ីលីធីនោះទេ។ គ្រឹះស្ថានត្រូវបកស្រាយជូនធនាគារជាតិនៃកម្ពុជា អំពីមូលហេតុនៃការធ្វើមុនហិរញ្ញប្បទានច្រើនដង ដែលជាប្រយោជន៍ដល់សមភាគីរបស់គ្រឹះស្ថាន។ ក្នុងពេលធ្វើមុនហិរញ្ញប្បទាន គ្រឹះស្ថានត្រូវរក្សាទុករាល់ប្រវត្តិទិន្នន័យទាក់ទងនឹងហ្វាស៊ីលីធីដែលបានធ្វើមុនហិរញ្ញប្បទាន និងការទូទាត់សងតាមគ្រានិងការទូទាត់សងចុងក្រោយ។ គ្រឹះស្ថានត្រូវបង្ហាញថាហ្វាស៊ីលីធីដែលបានធ្វើមុនហិរញ្ញប្បទានជាបន្តបន្ទាប់នេះ ស្ថិតនៅក្រោមដំណើរការផ្តល់ឥណទានដែលច្បាស់លាស់និងរឹងមាំ និងត្រូវបានទទួលការអនុមតិពីគណៈគ្រប់គ្រងដែលមានសិទ្ធិសម្រេច។

កត្តាដែលត្រូវយកចិត្តទុកដាក់ និងរក្សាទុកជាឯកសារក្នុងការធ្វើមុនហិរញ្ញប្បទាន ត្រូវមានលក្ខណៈស្រដៀងគ្នាទៅនឹងការផ្តល់ហ្វាស៊ីលីធីដំបូងដែរ រួមមាន ១). គោលបំណងនៃការប្រើប្រាស់ឥណទាន និងប្រភពនៃការទូទាត់សងហ្វាស៊ីលីធី ២). ទម្រង់ហានិភ័យបច្ចុប្បន្នរបស់សមភាគី រាប់បញ្ចូលទាំងប្រវត្តិនិងសមត្ថភាពបច្ចុប្បន្នក្នុងការទូទាត់សង និង ៣). ភាពគ្រប់គ្រាន់និងលទ្ធភាពអនុវត្តបានចំពោះទ្រព្យធានាឬការធានា។

**ប្រការ ៣៦.-**

"ហ្វាស៊ីលីធីរៀបចំឡើងវិញ" ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ២៣ ដល់ប្រការ ៣៣ នៃប្រកាសនេះ គឺជាផ្នែកមួយនៃ "មុនហិរញ្ញប្បទាន" ដែលផ្តល់ឲ្យតែក្នុងករណីសមភាគីជួបបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុរយៈពេល

បណ្តោះអាសន្ន។ នៅពេលធ្វើបុនហិរញ្ញប្បទានហ្វាស៊ីលីធី គ្រឹះស្ថានត្រូវពិនិត្យមើលថាតើបុនហិរញ្ញប្បទានធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងប្រការ ២៣ ខាងលើឬទេ។ ប្រសិនបើសមស្រប ហ្វាស៊ីលីធីថ្មីនោះត្រូវចាត់ទុកជា "ហ្វាស៊ីលីធីរៀបចំឡើងវិញ" និងត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងបញ្ញត្តិនៃប្រការ ២៣ ដល់ប្រការ ៣៣ នៃប្រកាសនេះ។

**ប្រការ ៣៧.-**

នៅពេលដែល "បុនហិរញ្ញប្បទាន" មិនមានលក្ខណៈគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌនៃ "ហ្វាស៊ីលីធីរៀបចំឡើងវិញ" "បុនហិរញ្ញប្បទាន" នោះអាចត្រូវបានធ្វើឡើងដើម្បីឲ្យសមភាគីដែលពុំមានស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុ អាចទទួលបានផលប្រយោជន៍អំពីលក្ខខណ្ឌនៃកិច្ចសន្យាឥណទានប្រសើរជាងមុន ដូចជាអត្រាការប្រាក់ល្អជាងមុន ការផ្លាស់ប្តូររវាងអត្រាការប្រាក់ថេរនិងអត្រាការប្រាក់ប្រែប្រួល ការកាត់បន្ថយចំនួនប្រាក់សងប្រចាំខែ ការកែប្រែរយៈពេលនៃកិច្ចសន្យា ការកើនឡើងទំហំប្រាក់កម្ចី ឬការគួបសរុបបំណុល។ បុនហិរញ្ញប្បទានមិនត្រូវធ្វើឡើងដើម្បីជំនួសពីការចាត់ថ្នាក់ហ្វាស៊ីលីធីដែលត្រូវបានកំណត់ថាមានអ៊ីមភែរមិន។

គ្រឹះស្ថានមិនអាចធ្វើបុនហិរញ្ញប្បទានជាមួយអតិថិជន នៅពេលដែលគ្រឹះស្ថានមានការសង្ស័យថាការទូទាត់សងហ្វាស៊ីលីធីជាបុនហិរញ្ញប្បទាន ត្រូវបានធ្វើឡើងដោយកម្ចីដែលបានមកពីអ្នកផ្តល់ផ្សេងទៀតដែលជាគ្រឹះស្ថាន ឬក៏បុគ្គលមិននៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៣៨.-**

គ្រឹះស្ថានត្រូវមានគោលនយោបាយនិងនីតិវិធីរឹងមាំជាលាយលក្ខណ៍អក្សរ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីកំណត់ស្ថានភាពនិងលក្ខខណ្ឌនៃហ្វាស៊ីលីធីដែលកំណត់ថាជា "បុនហិរញ្ញប្បទាន"។ គោលនយោបាយនិងនីតិវិធីនេះ ជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឥណទានដែលមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ក្នុងគោលដៅកំណត់អត្តសញ្ញាណ វាស់វែង តាមដាននិងត្រួតពិនិត្យហានិភ័យឥណទានរបស់គ្រឹះស្ថាន។

ទោះស្ថិតក្នុងបរិបទសេដ្ឋកិច្ចនិងស្ថានភាពហិរញ្ញវត្ថុណាក៏ដោយ គ្រឹះស្ថានមិនត្រូវធ្វើបុនហិរញ្ញប្បទានច្រើនដងលើហ្វាស៊ីលីធីរបស់សមភាគីតែមួយក្នុងរយៈពេលខ្លី ដើម្បីធ្វើឲ្យហ្វាស៊ីលីធីនេះជា "ហ្វាស៊ីលីធីល្អជានិច្ច" ដូចមានចែងក្នុងប្រការ ៣៥ នៃប្រកាសនេះ ឬដើម្បីគេចវេសពីការរៀបចំហ្វាស៊ីលីធីនេះឡើងវិញ ឬចាត់ថ្នាក់ជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន លើកលែងតែមានហេតុផលច្បាស់លាស់ និងត្រូវកត់ត្រាដោយហ្មត់ចត់។ គ្រឹះស្ថានអាចត្រូវបានតម្រូវឲ្យពិនិត្យនិងកែតម្រូវឡើងវិញ ចំពោះការធ្វើបុនហិរញ្ញប្បទានតាមរបៀបនេះ។

## ជំពូកទី ៦
## ទ្រព្យធានា

**ប្រការ ៣៩.-**

បញ្ញត្តិនៃប្រការ ៤០ ដល់ ប្រការ ៤៧ នៃប្រកាសនេះ គឺដើម្បីផ្តល់ការណែនាំអំពីទ្រព្យធានាដែលប្រើប្រាស់សម្រាប់ធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

**ប្រការ ៤០.-**

ទ្រព្យធានាត្រូវបានរក្សាទុកដើម្បីកាត់បន្ថយហានិភ័យឥណទាន។ ទ្រព្យធានាអាចជាទម្រង់នៃការធានាទ្រព្យ ឬប្រភេទផ្សេងៗនៃទ្រព្យសកម្ម ជាពិសេសទ្រព្យសកម្មហិរញ្ញវត្ថុជួញដូរបាន ដូចជា មូលបត្រកម្មសិទ្ធិនិងសញ្ញាបណ្ណជាដើម ដែលអាចជួញដូរបានយ៉ាងឆាប់រហ័សនៅក្នុងទីផ្សារតាមតម្លៃសមស្រប។

**ប្រការ ៤១.-**

ការវាយតម្លៃប្រកបដោយវិជ្ជាជីវៈមានសារៈសំខាន់ណាស់ក្នុងការប៉ាន់ស្មានតម្លៃជាក់ស្តែងនៃទ្រព្យធានា។ គ្រឹះស្ថានត្រូវមានគោលនយោបាយនិងនីតិវិធីជាលាយលក្ខណ៍អក្សរច្បាស់លាស់ក្នុងការកំណត់និងពិនិត្យលើតម្លៃទ្រព្យធានាណាមួយដែលដាក់ធានាចំពោះហ្វាស៊ីលីធី។ គោលនយោបាយនិងនីតិវិធីទាំងនេះ ត្រូវមានយ៉ាងតិច ដូចខាងក្រោម៖

១. សេចក្តីបញ្ជាក់អំពីទម្រង់ផ្សេងៗគ្នានៃទ្រព្យធានា និងលក្ខខណ្ឌដែលទ្រព្យធានានោះអាចទទួលយកបានដោយគ្រឹះស្ថាន

២. វិធីសាស្ត្រ និងមធ្យោបាយដែលរៀបចំដោយគ្រឹះស្ថាន ដើម្បីវិភាគយ៉ាងហ្មត់ចត់ទៅលើគុណភាពនិងតម្លៃទ្រព្យធានានោះ មុនពេលចុះកិច្ចសន្យាហ្វាស៊ីលីធីមានទ្រព្យធានា។ រាល់ទ្រព្យធានាត្រូវកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់ និងចងក្រងជាសំណុំឯកសារហ្វាស៊ីលីធីឲ្យបានត្រឹមត្រូវ។ គ្រឹះស្ថានត្រូវធានាថា រាល់កាតព្វកិច្ចផ្លូវច្បាប់ដែលពាក់ព័ន្ធត្រូវបានបំពេញ ដើម្បីរក្សាសិទ្ធិស្របច្បាប់លើទ្រព្យធានា និងអនុញ្ញាតឲ្យគ្រឹះស្ថានអាចអនុវត្តសិទ្ធិទាំងនោះបាន

៣. វិធីសាស្ត្រ និងមធ្យោបាយដែលរៀបចំឡើងដោយគ្រឹះស្ថាន ដើម្បីធ្វើបច្ចុប្បន្នកម្មការវាយតម្លៃទ្រព្យធានាឲ្យបានហ្មត់ចត់សម្រាប់អាយុកាលនៃហ្វាស៊ីលីធី។ ការធ្វើបច្ចុប្បន្នកម្មមានសារៈសំខាន់ជាពិសេសចំពោះ ១). តម្លៃទ្រព្យធានាងាយរងការប្រែប្រួលខ្លាំងទៅតាមពេលវេលា ២). ទ្រព្យធានាហ្វាស៊ីលីធីមានអនុបាតឥណទានធៀបនឹងតម្លៃទ្រព្យធានាកម្រិតខ្ពស់ និង ៣). ហ្វាស៊ីលីធីដែលមានអាយុកាលមធ្យមឬវែង។ ការវាយតម្លៃ និងការពិនិត្យឡើងវិញលើការវាយតម្លៃទ្រព្យធានាសម្រាប់អាយុកាលនៃហ្វាស៊ីលីធី ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន និងពិនិត្យលើពេលវេលា បន្ទុកចំណាយ និងការលំបាកផ្សេងៗពាក់ព័ន្ធនឹងការលក់ទ្រព្យធានានោះ និង

៤. ការពិនិត្យឡើងវិញជាទៀងទាត់នូវលទ្ធភាពទទួលបានការទូទាត់សងពីការលក់ទ្រព្យធានាក្នុងអាយុកាលនៃហ្វាស៊ីលីធី។

**ប្រការ ៤២.-**

ទ្រព្យសកម្មដែលទទួលយកជាទ្រព្យធានាត្រូវបានវាយតម្លៃតាមតម្លៃជាក់ស្តែង ដោយប្រើប្រាស់វិធីសាស្ត្រស្របតាមស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

**ប្រការ ៤៣.-**

មុនពេលចុះកិច្ចសន្យាហ្វាស៊ីលីធីមានទ្រព្យធានាថ្មី គ្រឹះស្ថានត្រូវវិភាគគុណភាព និងតម្លៃទ្រព្យធានាឲ្យបានហ្មត់ចត់ ព្រមទាំងសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការអនុវត្តសិទ្ធិលើទ្រព្យធានា ដើម្បីទូទាត់សងគ្រប់ចំនួនតាមកិច្ចសន្យា ក្នុងករណីសមភាគីខកខានមិនបានបំពេញតាមកិច្ចសន្យា។

**ប្រការ ៤៤.-**

ក្នុងការកំណត់តម្លៃជាក់ស្តែងនៃទ្រព្យធានា គ្រឹះស្ថានត្រូវផ្អែកលើអ្នកវាយតម្លៃទ្រព្យធានាផ្ទៃក្នុង និង/ឬខាងក្រៅ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់។ គោលនយោបាយនិងនីតិវិធីដែលមានចែងក្នុងប្រការ ៤១ នៃប្រកាសនេះ ត្រូវបញ្ជាក់ឲ្យច្បាស់អំពីលក្ខខណ្ឌនៃការវាយតម្លៃទ្រព្យធានានោះ។

**ប្រការ ៤៥.-**

អ្នកវាយតម្លៃផ្ទៃក្នុងនិងខាងក្រៅរបស់គ្រឹះស្ថានត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់និងបទពិសោធន៍វិជ្ជាជីវៈក្នុងការវាយតម្លៃទ្រព្យធានា។ គ្រឹះស្ថានត្រូវជ្រើសរើសអ្នកវាយតម្លៃខាងក្រៅ ពីបញ្ជីឈ្មោះក្រុមហ៊ុនវាយតម្លៃដែលទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤៦.-**

រយៈពេលសម្រាប់លក់ទ្រព្យធានាគឺជាកត្តាសំខាន់នៅពេលវាយតម្លៃទ្រព្យធានាលើហិរញ្ញប្បទានឥណទាន។ ជាទូទៅ រយៈពេល ១២ ខែ ជារយៈពេលសមស្រប លើកលែងតែកាលៈទេសៈពិសេស ដែលទាមទាររយៈពេលវែងជាងនេះ។ ក្នុងករណីរយៈពេលវែងជាង ១២ ខែ គ្រឹះស្ថានត្រូវជ្រើសរើសយករយៈពេលវែងបំផុតសម្រាប់កំណត់តម្លៃជាក់ស្តែង។

**ប្រការ ៤៧.-**

ក្នុងករណី "តម្លៃជាក់ស្តែង" នៃទ្រព្យធានាត្រូវបានកំណត់ដោយផ្អែកលើតម្លៃទីផ្សារអាចជឿជាក់បាន គ្រឹះស្ថានត្រូវពិនិត្យលើការកំណត់យកទីផ្សារសមស្រប សន្ទនីយភាពនៃទ្រព្យធានាក្នុងទីផ្សារនោះ រយៈពេលលក់ ចំណាយផ្សេងៗពាក់ព័ន្ធនឹងការលក់ និងផលប៉ះពាល់ធ្ងន់ធ្ងរដែលអាចកើតឡើងពីការលក់ទៅលើតម្លៃទីផ្សារ។

## ជំពូកទី ៧
## ការទទួលស្គាល់ និងការវាស់វែង ហិរញ្ញប្បទានដែលមានអ៊ីមភែរមិន

**ប្រការ ៤៨.-**

ការទទួលស្គាល់ និងការវាស់វែងសមស្របចំពោះហិរញ្ញប្បទានដែលមានអ៊ីមភែរមិន ជាធាតុដ៏សំខាន់ក្នុងការរៀបចំគោលនយោបាយធ្វើសំវិធានធនរបស់គ្រឹះស្ថាន ហើយជាពិសេសសម្រាប់វាយតម្លៃលើភាពគ្រប់គ្រាន់នៃដើមទុន។

បញ្ញត្តិនៃប្រការ ៤៩ ដល់ ប្រការ ៧១ នៃប្រកាសនេះ គឺជាការណែនាំអប្បបរមាសម្រាប់ការទទួលស្គាល់ហិរញ្ញប្បទានដែលមានអ៊ីមភែរមិន និងការវាស់វែងសំវិធានធនតាមស្តង់ដារគណនេយ្យជាធរមាន។

**ប្រការ ៤៩.-**

វិសាលភាពនៃហិរញ្ញប្បទានដែលមានអ៊ីមភែរមិន ត្រូវគិតបញ្ចូលទ្រព្យសកម្មទាំងអស់ដែលមានទាំងនៅក្នុងនិងក្រៅតារាងតុល្យការ។ ក្នុងការទទួលស្គាល់ហិរញ្ញប្បទានដែលមានអ៊ីមភែរមិន គ្រឹះស្ថានមិនត្រឹមតែកំណត់ចំពោះការផ្តល់កម្ចីប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតបញ្ចូលហិរញ្ញប្បទានផ្សេងទៀតដែលនាំឲ្យមានហានិភ័យឥណទានជាមួយសមភាគីផងដែរ។ គ្រឹះស្ថានត្រូវទទួលស្គាល់ហិរញ្ញប្បទានដែលមានអ៊ីមភែរមិន ស្របតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវកំណត់ដោយស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

ហិរញ្ញប្បទានដែលត្រូវទទួលស្គាល់ថាមានអ៊ីមភែរមិន នៅពេលដែលមានការសង្ស័យថាទឹកប្រាក់ជំពាក់សរុប រួមទាំងការប្រាក់ និងទឹកប្រាក់ផ្សេងៗទៀត មិនត្រូវបានទូទាត់សងទាន់ពេលវេលា ដោយមិនគិតពីរយៈពេលហួសកាលកំណត់ ៩០ ថ្ងៃ (៦០ ថ្ងៃ សម្រាប់ហិរញ្ញប្បទានរយៈពេលខ្លី) ឬច្រើនជាង។ ហិរញ្ញប្បទានក៏ត្រូវទទួលស្គាល់ថាមានអ៊ីមភែរមិនដែរ ទោះបីជាទំហំនៃការបាត់បង់ទាំងអស់មិនអាចកំណត់បានច្បាស់លាស់ក៏ដោយ។

កត្តាមួយចំនួនដែលនាំឲ្យមានការសង្ស័យ និងតម្រូវឲ្យចាត់ថ្នាក់សមតុល្យហិរញ្ញប្បទានដក់សល់ថាមានអ៊ីមភែរមិន មានដូចខាងក្រោម៖

១. ហិរញ្ញប្បទានដែលមានការទូទាត់សងប្រចាំខែ ឬតិចជាង និងហួសកាលកំណត់ ៩០ ថ្ងៃ (៦០ ថ្ងៃ សម្រាប់ហិរញ្ញប្បទានរយៈពេលខ្លី) ដោយមិនមានការធានាត្រឹមត្រូវនិងគ្រប់គ្រាន់

២. សមភាគីដែលទទួលបានហិរញ្ញប្បទាន ប្រឈមនឹងការបរាជ័យ ឬនីតិវិធីក្ស័យធន លើកលែងតែហិរញ្ញប្បទានមានការធានាត្រឹមត្រូវនិងគ្រប់គ្រាន់ ឬ

៣. ការលុបចោលផ្នែកខ្លះនៃហិរញ្ញប្បទាន ទោះបីក្នុងហេតុផលណាក៏ដោយ។

កត្តាដទៃទៀតដែលអាចបញ្ជាក់ពីអ៊ីមភែរមិននៃហ្វាស៊ីលីធី មានដូចខាងក្រោម៖

១. ការលំបាកធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុរបស់សមភាគី

២. ការអនុគ្រោះដែលគ្រឹះស្ថានផ្តល់ទៅឱ្យសមភាគីនៅពេលសមភាគីជួបការលំបាកផ្នែកហិរញ្ញវត្ថុ ឬ

៣. ព័ត៌មានឬទិន្នន័យណាមួយបញ្ជាក់ថាមានការថយចុះនៃលំហូរសាច់ប្រាក់រំពឹងទុកដែលនឹងប្រមូលបានពីសមភាគី និងការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក និងសកល ដែលជះឥទ្ធិពលដល់លំហូរសាច់ប្រាក់រំពឹងទុកនោះ។

ការទូទាត់សងតាមគ្រានីមួយៗត្រូវធ្វើឡើងឱ្យបានគ្រប់ចំនួន។ សម្រាប់ការគណនាហ្វាស៊ីលីធីសងយឺត ការទូទាត់សងតែមួយចំណែកនៃការសងតាមគ្រា ត្រូវចាត់ទុកថាជាការសងយឺត។

នៅពេលដែលការទូទាត់សងត្រូវបានកំណត់ក្នុងរយៈពេល ៩០ ថ្ងៃ ឬវែងជាងនេះ ហ្វាស៊ីលីធីត្រូវបានចាត់ថាមានអ៊ីមភែរមិនភ្លាម ក្នុងករណីដែលមានការខកខានទូទាត់សង លើកលែងតែគ្រឹះស្ថានអាចបង្ហាញថាហ្វាស៊ីលីធីមិនមានភាពទន់ខ្សោយណាមួយដែលនាំឱ្យមានការចាត់ថ្នាក់ក្រោមស្តង់ដារ ឬអន់ជាងនេះ។ ការខកខានទូទាត់សងត្រូវគិតចាប់ពី ០៥ ថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទទូទាត់សង។

ឥណទានវិបារូបន៍ និងហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញ (Revolving Facilities) ផ្សេងៗទៀតដែលបន្តមានសមតុល្យលើសកម្រិតអនុម័ត ក្នុងរយៈពេល ៩០ ថ្ងៃ (៦០ ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី) ឬលើសពីនេះបន្តបន្ទាប់គ្នា ត្រូវចាត់ទុកជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។ ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនត្រូវគិតលើសមតុល្យសរុបដក់សល់នៃហ្វាស៊ីលីធីនោះ។

ការសន្យាផ្តល់ឥណទាន (Loan commitment facilities) ដែលមិនអាចកែប្រែបាន (Irrevocable) ត្រូវបានចាត់ថ្នាក់ថាមានអ៊ីមភែរមិន នៅពេលដែលសមត្ថភាពទូទាត់សង (Creditworthiness) របស់សមភាគីថយចុះ ដែលនាំឱ្យមានការសង្ស័យអំពីលទ្ធភាពទូទាត់សងប្រាក់គ្រប់ចំនួន និងទាន់ពេលវេលាចំពោះការប្រើប្រាស់ឥណទាន និង/ឬ ការទូទាត់ការប្រាក់ ឬសោហ៊ុយផ្សេងៗ។

ហ្វាស៊ីលីធីផ្សេងទៀតនៃខ្ទង់ក្រៅតារាងតុល្យការ ក៏ត្រូវអនុវត្តតាមប្រកាសនេះដែរ។ ហ្វាស៊ីលីធីដែលមានលក្ខណៈជំនួសឥណទាន (Direct credit substitutes) ដូចជា ការធានា និងលិខិតឥណទាន ដែលជាទូទៅនឹងក្លាយជាខ្ទង់ក្នុងតារាងតុល្យការនៅពេលប្រើប្រាស់។ គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីថាមានអ៊ីមភែរមិនក្នុងករណីគ្រឹះស្ថានមានហេតុផលច្បាស់លាស់ថា ឧបករណ៍ខាងលើនេះ នឹងត្រូវប្រើប្រាស់ដោយសមភាគីនាពេលអនាគតក្នុងកាលៈទេសៈ ដែលគ្រឹះស្ថានជឿជាក់ថាមិនអាចប្រមូលមកវិញគ្រប់ចំនួនបានទាន់ពេលវេលាចំពោះទឹកប្រាក់ដែលគ្រឹះស្ថាននឹងត្រូវទូទាត់សងជំនួស។

ហានិភ័យនៃការខាតបង់ ក៏អាចកើតឡើងពីហ្វាស៊ីលីធីផ្សេងៗទៀតក្នុងខ្ទង់ក្រៅតារាងតុល្យការដែរ ដូចជា ប្រតិបត្តិការនិស្សន្ទ ជាពិសេសនៅពេលដែលចំណាត់ថ្នាក់ឥណទានរបស់សមភាគីធ្លាក់ចុះ។ គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីនេះថាមានអ៊ីមភែរមិន នៅពេលមានការសង្ស័យថា មិនអាចទទួលបានលំហូរសាច់ប្រាក់ដែលដល់ ឬនឹងដល់ពេលទូទាត់សងគ្រប់ចំនួន និងទាន់ពេលវេលាពីសមភាគី។

**ប្រការ ៥០.-**

គ្រឹះស្ថានត្រូវធានាថា ការទទួលស្គាល់ និងការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គោរពតាមគោលការណ៍និងលក្ខខណ្ឌតម្រូវកំណត់ដោយស្តង់ដារគណនេយ្យជាធរមាននៃប្រទេសកម្ពុជា។

ការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដែលអនុវត្តតាមវិធីសាស្ត្ររំលស់ថ្លៃដើម ត្រូវធ្វើឡើងជាលើកដំបូងតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" លើកលែងតែចំពោះហ្វាស៊ីលីធីដែលមានចរិតលក្ខណៈប្រហាក់ប្រហែលគ្នា និងស្ថិតនៅក្រោមកម្រិតកំណត់ជាសារវន្ត ត្រូវវាយតម្លៃជាក្រុម។ ហ្វាស៊ីលីធីដែលត្រូវ

បានវាយតម្លៃជាក្រុម និងស្ថិតនៅក្រោមកម្រិតកំណត់ជាសារវន្ត មានដូចជា ប័ណ្ណឥណទាន ឥណទានសម្រាប់អ្នកប្រើប្រាស់តូចៗ រួមទាំងឥណទានយានយន្ត ជាដើម។

ក្នុងការវាយតម្លៃលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" គ្រឹះស្ថានត្រូវបែងចែកសំពៀតហ្វាស៊ីលីធីជាក្រុមៗតាមការចាំបាច់ ដើម្បីប្រមូលផ្តុំហ្វាស៊ីលីធីដែលមានចរិតលក្ខណៈ និងមានហានិភ័យឥណទានប្រហាក់ប្រហែលគ្នា ដូចជា ប្រភេទហ្វាស៊ីលីធី ប្រភេទសមភាគី ស្ថានភាពហួសកាលកំណត់ ចំណាត់ថ្នាក់ហានិភ័យឥណទាន ប្រភេទទ្រព្យធានា និងស្ថានភាពភូមិសាស្ត្រ។ ការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នា ទៅតាមប្រភេទក្រុមនីមួយៗ។

នៅពេលដែលសមភាគីមួយមានហ្វាស៊ីលីធីច្រើន ដោយក្នុងនោះ ហ្វាស៊ីលីធីមួយមានទំហំលើសពីកម្រិតកំណត់ជាសារវន្ត និងត្រូវបានចាត់ថ្នាក់ថាមានអ៊ីមភែរមិន ឬផលបូកសរុបនៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនលើសកម្រិតកំណត់ជាសារវន្ត ការវាស់វែងលើហ្វាស៊ីលីធីទាំងនោះត្រូវធ្វើឡើងតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ទោះបីជាហ្វាស៊ីលីធីផ្សេងទៀតដែលផ្តល់ទៅឲ្យសមភាគីនោះស្ថិតនៅក្រោមកម្រិតកំណត់ជាសារវន្តក៏ដោយ។

**ប្រការ ៥១**.-

ហ្វាស៊ីលីធីទាំងឡាយណាដែលត្រូវបានវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ដូចមានចែងក្នុងប្រការ ៥០ នៃប្រកាសនេះ បានបង្ហាញថាមិនមានអ៊ីមភែរមិន និងមិនត្រូវបានធ្វើសំវិធានធនលើហ្វាស៊ីលីធីទោល នឹងត្រូវដាក់បញ្ចូលគ្នាទៅក្នុងក្រុមហ្វាស៊ីលីធីដែលមានចរិតលក្ខណៈហានិភ័យស្រដៀងគ្នា ដើម្បីវាយតម្លៃជាលើកទីពីរ តាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ដោយអនុវត្តវិធីសាស្ត្រដូចទៅនឹងក្រុមហ្វាស៊ីលីធីដែលស្ថិតក្រោមកម្រិតកំណត់។ ការដាក់បញ្ចូលជាក្រុមនេះ ត្រូវតែកែសម្រួលឲ្យសមស្របតាមទំហំ និងប្រភេទនៃហ្វាស៊ីលីធីដែលត្រូវបានវាយតម្លៃ។ ហ្វាស៊ីលីធីដែលមានទឹកប្រាក់ខ្ពស់លើសលប់ និងពិសេសជាងគេ អាចត្រូវលើកលែងពីការវាយតម្លៃក្នុងដំណាក់កាលទីពីរ ប៉ុន្តែការលើកលែងនេះ អនុវត្តចំពោះតែហ្វាស៊ីលីធីពិសេសដែលមានចំនួនតិចតួចប៉ុណ្ណោះ។

**ប្រការ ៥២**.-

អ៊ីមភែរមិននៃហ្វាស៊ីលីធីទោល ឬហ្វាស៊ីលីធីក្រុមស្រដៀងគ្នា ដែលអនុវត្តតាមវិធីសាស្ត្ររំលស់ថ្លៃដើម ត្រូវបានគណនាតាមវិធីសាស្ត្រ "ការខាតបង់ឥណទានរំពឹងទុក" (Expected Credit Losses - ECL) ដែលជាការប៉ាន់ស្មានការខាតបង់ឥណទានថ្លឹងតាមប្រូបាប៊ីលីតេ (កង្វះសាច់ប្រាក់គិតក្នុងតម្លៃបច្ចុប្បន្ន - Present value of all cash shortfalls) សម្រាប់រយៈពេលទាំងស្រុងនៃកិច្ចសន្យាហ្វាស៊ីលីធី។ កង្វះសាច់ប្រាក់ត្រូវបានគណនាដោយយកលំហូរសាច់ប្រាក់ដែលត្រូវទទួលបានដោយគ្រឹះស្ថានទៅតាមកិច្ចសន្យា ដក លំហូរសាច់ប្រាក់ដែលគ្រឹះស្ថានរំពឹងថានឹងទទួលបាន។ ប្រសិនបើនៅកាលបរិច្ឆេទរាយការណ៍ ហានិភ័យឥណទាននៃហ្វាស៊ីលីធីមិនមានការកើនឡើងខ្លាំងធៀបនឹងកាលបរិច្ឆេទទទួលស្គាល់ដំបូង គ្រឹះស្ថានត្រូវធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីក្នុងចំនួនស្មើនឹងការខាតបង់ឥណទានរំពឹងទុករយៈពេល ១២ ខែ ប៉ុណ្ណោះ។ លក្ខខណ្ឌលម្អិតនៃការគណនាការខាតបង់ឥណទានរំពឹងទុកត្រូវផ្អែកលើគោលការណ៍ និងលក្ខខណ្ឌតម្រូវកំណត់ដោយស្តង់ដារគណនេយ្យជាតរមោននៃប្រទេសកម្ពុជា។

**ប្រការ ៥៣**.-

ចំពោះ ឥណទានស៊ីនឌីខេត (Syndicated loans) គ្រឹះស្ថាននីមួយៗដែលចូលរួមផ្តល់ឥណទានត្រូវទទួលខុសត្រូវរក្សាព័ត៌មានឥណទានរបស់សមភាគីឲ្យបានគ្រប់គ្រាន់ ដើម្បីវាយតម្លៃ និងធ្វើសំវិធានធនទៅលើចំណែកនៃឥណទានស៊ីនឌីខេតរបស់ខ្លួន។ គ្រឹះស្ថានដឹកនាំត្រូវចែករំលែកព័ត៌មានឥណទានរបស់សមភាគីដែលធ្វើបច្ចុប្បន្នកម្មចុងក្រោយដល់គ្រប់គ្រឹះស្ថានចូលរួមទាំងអស់។ នៅពេលដែលមានព័ត៌មានគួរឲ្យ

យកចិត្តទុកដាក់ថា គ្រឹះស្ថានចូលរួមដែលជាគ្រឹះស្ថានដឹកនាំ ឬគ្រឹះស្ថានចូលរួមណាមួយបានបន្ថយចំណាត់ថ្នាក់ឥណទានស៊ីនឌីខេត គ្រឹះស្ថានត្រូវបន្ថយចំណាត់ថ្នាក់ឥណទានស៊ីនឌីខេតនោះ តាមចំណែករបស់ខ្លួន។

**ប្រការ ៥៤.-**

គ្រឹះស្ថានមិនត្រូវលាយកិច្ចសន្យាមុនឥណប្រតិទាន ចំពោះហ្វាស៊ីលីធីណាមួយ នៅពេលដែលគ្រឹះស្ថានផ្តល់ហ្វាស៊ីលីធីថ្មីមួយទៀត ទៅឲ្យសមភាគីតែមួយ ឬសម្ព័ន្ធបុគ្គលដែលទាក់ទងនឹងសមភាគី ដើម្បីជៀសវាងពីការចាត់ថ្នាក់ឥណទានដំបូងថាមានអ៊ីមភែរមិន។ ក្នុងករណី គ្រឹះស្ថានផ្តល់ហ្វាស៊ីលីធីថ្មី ហ្វាស៊ីលីធីនេះ ត្រូវចាត់ថ្នាក់ថាមានអ៊ីមភែរមិនភ្លាមនៅពេលអនុម័ត។

**ប្រការ ៥៥.-**

គ្រឹះស្ថានត្រូវមាន គោលនយោបាយ នីតិវិធី ប្រព័ន្ធព័ត៌មានវិទ្យា និងដំណើរការ ប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាការទទួលស្គាល់និងការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ធ្វើឡើងបានទាន់ពេលវេលា និងអាចជឿជាក់បាន។ គោលនយោបាយនិងនីតិវិធីទាំងនេះ ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល និងត្រូវមានចែងអំពីក្របខ័ណ្ឌវិភាគសម្រាប់វាយតម្លៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។ គោលនយោបាយនិងនីតិវិធីត្រូវមានចែងជាអប្បបរមា ដូចតទៅ៖

១. កំណត់តួនាទីនិងការទទួលខុសត្រូវរបស់ ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ត្រូវចូលរួមរៀបចំក្របខ័ណ្ឌវិភាគសម្រាប់វាយតម្លៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន

២. កំណត់អត្តសញ្ញាណចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន

៣. កំណត់ហ្វាស៊ីលីធីណា ដែលត្រូវវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" និងហ្វាស៊ីលីធីណាដែលត្រូវវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម"។ គ្រឹះស្ថានត្រូវមានលទ្ធភាពពន្យល់បង្ហាញដល់ធនាគារជាតិនៃកម្ពុជាថា គោលនយោបាយរបស់ខ្លួនក្នុងការកំណត់ហ្វាស៊ីលីធី ដែលត្រូវបានវាយតម្លៃនិងគ្រប់គ្រង តាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម" ត្រូវផ្តល់ការវិភាគដោយប្រុងប្រយ័ត្នទៅលើហានិភ័យឥណទាន ដែលអាចកើតមានចំពោះហ្វាស៊ីលីធីទោល

៤. កំណត់ពីវិធីសាស្ត្រវាស់វែងទំហំហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និង

៥. ពិនិត្យឡើងវិញជាទៀងទាត់លើ ទំហំ និងវិធីសាស្ត្រវាស់វែងទំហំហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។

គោលនយោបាយនិងនីតិវិធីទាំងនោះត្រូវមានចែងអំពី ការប្រមូលនិងរក្សាទិន្នន័យទាំងអស់ រួមទាំងព័ត៌មានផ្សេងទៀតដើម្បីជួយដល់ការធ្វើសំវិធានធនឲ្យបានគ្រប់គ្រាន់។ គោលនយោបាយនិងនីតិវិធីនេះរួមបញ្ចូលទាំងការរក្សាទុកគ្រប់ទិន្នន័យមានគុណភាពខ្ពស់ទាំងប្រភេទនិងទំហំ ដែលចាំបាច់សម្រាប់ប្រើប្រាស់ក្នុងម៉ូដែលហានិភ័យឥណទាន (Credit risk models) បច្ចេកទេសស្ថិតិ (Statistical techniques) និងវិធីសាស្ត្រដទៃទៀត ដែលប្រើប្រាស់ដោយគ្រឹះស្ថានក្នុងការវាយតម្លៃហានិភ័យឥណទាន។ គ្រឹះស្ថានត្រូវធានាភាពត្រឹមត្រូវនៃទិន្នន័យនិងព័ត៌មាន។

**ប្រការ ៥៦.-**

គ្រឹះស្ថានត្រូវបង្កើតនិងរក្សាប្រព័ន្ធពិនិត្យឥណទានឡើងវិញ ប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់តាមដាន និងគ្រប់គ្រងគុណភាពទ្រព្យសកម្មឲ្យបានត្រឹមត្រូវ មានលក្ខណៈជាប្រព័ន្ធ និងទាន់ពេលវេលាស្របតាមគោលការណ៍ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ៥ ដល់ ប្រការ ១០ នៃប្រកាសនេះ។ ជាផ្នែកមួយនៃដំណើរការពិនិត្យឥណទានឡើងវិញ គ្រឹះស្ថានត្រូវបង្កើតយន្តការនិងវាយតម្លៃជាប្រចាំនូវភាពគ្រប់គ្រាន់នៃ

ការធ្វើសំវិធានធន សម្រាប់ទប់ទល់នឹងការខាតបង់រំពឹងទុក ដែលអាចកើតចេញពីសំពៀតឥណទាន ដោយគិតបញ្ចូលកត្តាទាំងអស់ដែលបង្ហាញពីភាពថមថយសមត្ថភាពរបស់គ្រឹះស្ថាន ក្នុងការប្រមូលប្រាក់ដែលដល់កាលកំណត់សងពីសមភាគី។

ក្នុងការទទួលស្គាល់និងការវាស់វែងហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គ្រឹះស្ថានត្រូវពិនិត្យឥណទានឡើងវិញទៅលើហ្វាស៊ីលីធីទាំងអស់ រួមទាំងហ្វាស៊ីលីធីដែលត្រូវបានចាត់ថ្នាក់ជា "ធម្មតា" និង "ឃ្លាំមើល"។

**ប្រការ ៥៧.-**

ផ្នែកទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយនិងនីតិវិធីនៃការចាត់ថ្នាក់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនរបស់គ្រឹះស្ថាន ត្រូវមានបុគ្គលិកដែលមានសមត្ថភាពនិងទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ។ គោលនយោបាយនិងនីតិវិធីទាំងនេះ ត្រូវបានពិនិត្យឡើងវិញតាមគ្រាជាប្រចាំ ដោយសវនកម្មផ្ទៃក្នុង និងក្រុមហ៊ុនសវនកម្ម ហើយលទ្ធផលនៃការធ្វើសវនកម្ម ត្រូវរាយការណ៍ទៅក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងជាន់ខ្ពស់។ គ្រឹះស្ថានត្រូវកែតម្រូវភ្លាមៗនូវរាល់ចំណុចខ្វះខាតដែលបានរកឃើញ ដោយបុគ្គលិកទទួលបន្ទុកផ្នែកឥណទាន ឬដោយបុគ្គលិកទទួលបន្ទុកអនុវត្តគោលនយោបាយ និងនីតិវិធីនេះ ឬដោយសវនករផ្ទៃក្នុង ឬក្រុមហ៊ុនសវនកម្ម។

**ប្រការ ៥៨.-**

ការទទួលស្គាល់ និងការវាស់វែងអ៊ីមភែរមិននៃហ្វាស៊ីលីធី មិនពឹងផ្អែកតែលើរូបមន្ត និងវិធាននានាទេ តែតម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យផ្អែកលើបទពិសោធន៍ផ្នែកឥណទាន។ វិសាលភាពនៃការសម្រេចជាឆន្ទានុសិទ្ធិរបស់គណៈគ្រប់គ្រងក្នុងការវាយតម្លៃអ៊ីមភែរមិននៃហ្វាស៊ីលីធី ត្រូវមានកំណត់ដោយប្រុងប្រយ័ត្ន ហើយដំណើរការវិនិច្ឆ័យត្រូវកត់ត្រា និងមានឯកសារគ្រប់គ្រាន់ដែលមានលក្ខណៈងាយយល់។ គ្រឹះស្ថានត្រូវបង្ហាញថាការវិនិច្ឆ័យនេះនឹងមិននាំឱ្យមានការរាយការណ៍ខុសជាប្រព័ន្ធចំពោះការប៉ាន់ស្មានអ៊ីមភែរមិននៃហ្វាស៊ីលីធីនិងការធ្វើសំវិធានធន។ ការវិនិច្ឆ័យត្រូវផ្អែកលើសម្មតិកម្មគ្រប់គ្រាន់នៅគ្រប់កាលៈទេសៈពាក់ព័ន្ធ និងធ្វើឡើងដោយប្រុងប្រយ័ត្ន។ ការវិនិច្ឆ័យនេះអាចមានសារៈសំខាន់៖

១. សម្រាប់កំណត់រយៈពេលសមស្របដែលអាចអនុញ្ញាតឱ្យគណនាទិន្នន័យអំពីប្រវត្តិហ្វាស៊ីលីធីខាតបង់។ ដើម្បីកំណត់ពីទិន្នន័យជាមធ្យមនៃហ្វាស៊ីលីធីបាត់បង់ដែលធ្លាប់កើតមានសម្រាប់ក្រុមហ្វាស៊ីលីធីណាមួយ គ្រឹះស្ថានមិនត្រូវកំណត់យកតែរយៈពេលថេរឡើយ។ ក្នុងអំឡុងពេលសេដ្ឋកិច្ចមានស្ថិរភាព គ្រឹះស្ថានអាចប្រើប្រាស់ទិន្នន័យអំពីប្រវត្តិហ្វាស៊ីលីធីខាតបង់រយៈពេលវែង (លើសពី ០៥ ឆ្នាំ) ចំណែកឯក្នុងអំឡុងពេលសេដ្ឋកិច្ចមានការប្រែប្រួលខ្លាំង គ្រឹះស្ថានអាចប្រើប្រាស់ទិន្នន័យរយៈពេលខ្លីជាងនេះ ឬ

២. សម្រាប់ករណីដែលគ្រឹះស្ថានមិនមានទិន្នន័យអំពីប្រវត្តិហ្វាស៊ីលីធីខាតបង់គ្រប់គ្រាន់ ឬទិន្នន័យទាំងនោះមិនអាចឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្នបាន។

**ប្រការ ៥៩.-**

ការកែសម្រួលទៅលើទិន្នន័យនិងបទពិសោធន៍នៃប្រវត្តិហ្វាស៊ីលីធីខាតបង់ ត្រូវមានចំណុចយ៉ាងតិចដូចខាងក្រោម៖

១. ការប្រែប្រួលទៅលើកម្រិតនិងនិន្នាការនៃអត្រាសងយឺតនិងទំហំនៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន
២. ការប្រែប្រួលទៅលើការបែងចែក និងការប្រមូលផ្តុំឥណទាន
៣. ការកែប្រែគោលនយោបាយនិងនីតិវិធីឥណទានរបស់គ្រឹះស្ថាន
៤. ការប្រែប្រួលការរៀបចំហ្វាស៊ីលីធីឡើងវិញ

៥. ការប្រែប្រួលបទពិសោធន៍ និងសមត្ថភាពរបស់គណៈគ្រប់គ្រងរបស់គ្រឹះស្ថានក្នុងការគ្រប់គ្រងហានិភ័យឥណទាន និងក្នុងការប្រមូលត្រឡប់មកវិញនូវចំនួនទឹកប្រាក់ដែលហួសកាលកំណត់សង និង

៦. ការប្រែប្រួលស្ថានភាព និងនិន្នាការសេដ្ឋកិច្ចក្នុងស្រុកនិងសកល ទាំងបច្ចុប្បន្ន និងរំពឹងទុក។

**ប្រការ ៦០.-**

នៅពេលគ្រឹះស្ថានផ្តល់ហ្វាស៊ីលីធីច្រើនទៅឱ្យសមភាគីតែមួយ ឬក្រុមសម្ព័ន្ធសមភាគី គ្រឹះស្ថានត្រូវមានគោលនយោបាយនិងនីតិវិធី ដើម្បីធានាថា ប្រសិនបើហ្វាស៊ីលីធីណាមួយត្រូវបានចាត់ថ្នាក់ថាមានអ៊ីមភែរមិន គ្រឹះស្ថានត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីដទៃទៀតជាហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនដូចគ្នា លើកលែងតែក្នុងករណីដូចខាងក្រោម៖

១. ហ្វាស៊ីលីធីផ្សេងៗ មិនត្រូវបានធានាដោយទ្រព្យធានារួម និងមិនមានការធានាទៅវិញទៅមករវាងសមភាគីសម្ព័ន្ធញាតិ ឬ

២. ហ្វាស៊ីលីធីដែលមានទ្រព្យធានារួម និង/ឬ ការធានាទៅវិញទៅមក ប៉ុន្តែ សមភាគី ឬសមភាគីសម្ព័ន្ធញាតិមានការធានាគ្រប់គ្រាន់ ក្នុងការប្រមូលគ្រប់ចំនួននូវការទូទាត់សងដែលដល់កាលកំណត់ រួមមាន ប្រាក់ដើម ការប្រាក់ និងបំណុលផ្សេងៗ ទាំងចំពោះហ្វាស៊ីលីធីមាន និងមិនមានអ៊ីមភែរមិន។

**ប្រការ ៦១.-**

ជាផ្នែកមួយនៃការវាស់វែងកម្រិតអ៊ីមភែរមិននៃហ្វាស៊ីលីធី គ្រឹះស្ថានត្រូវមានគោលនយោបាយ និងនីតិវិធីដើម្បីធានាបាននូវភាពជឿទុកចិត្តបាន សង្គតិភាព និងភាពប្រុងប្រយ័ត្ន ចំពោះការប៉ាន់ស្មានការទូទាត់នាពេលអនាគតលើប្រាក់ដើមនិងការប្រាក់ ដែលបានប្រើប្រាស់ក្នុងការកំណត់កម្រិតអ៊ីមភែរមិននៃហ្វាស៊ីលីធី។

**ប្រការ ៦២.-**

គ្រឹះស្ថានមិនត្រូវប្រើទ្រព្យធានាធ្វើជាហេតុផលជំនួសកង្វះព័ត៌មានរបស់សមភាគី ឬកង្វះការវិភាគរបស់គ្រឹះស្ថាន ក្នុងការតាមដានជាប្រចាំអំពីការបំពេញកាតព្វកិច្ចស្របតាមកិច្ចសន្យារបស់សមភាគី។ លើសពីនេះ គ្រឹះស្ថានក៏មិនត្រូវប្រើទ្រព្យធានាធ្វើជាហេតុផលជំនួសការវិភាគរបស់គ្រឹះស្ថាន ក្នុងការវាយតម្លៃជាប្រចាំនូវកម្រិតអ៊ីមភែរមិននៃហ្វាស៊ីលីធី និងតម្រូវការធ្វើសំវិធានធនលើអ៊ីមភែរមិន។

**ប្រការ ៦៣.-**

ក្នុងការវាយតម្លៃអ៊ីមភែរមិននៃហ្វាស៊ីលីធី គ្រឹះស្ថានត្រូវពិនិត្យទាំងកត្តាខាងក្នុង និងខាងក្រៅ ដែលអាចបង្ហាញពីការថយចុះលទ្ធភាព ឬគ្មានលទ្ធភាពប្រមូលការទូទាត់សង ដែលដល់កាលកំណត់តាមកិច្ចសន្យារបស់សមភាគី។ កត្តាទាំងនេះ រួមមាន៖

១. ការថយចុះលទ្ធភាពទូទាត់សងរបស់សមភាគី ដែលត្រូវធ្វើសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ របស់ក្រុមសមភាគីដែលត្រូវធ្វើសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម"

២. ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកដែលអាចមានផលប៉ះពាល់ដល់លទ្ធភាពសងរបស់សមភាគី

៣. ព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងបម្រែបម្រួលសំខាន់ៗក្នុងស្រុក និងអន្តរជាតិ ដែលមានឥទ្ធិពលអវិជ្ជមានដល់ស្ថានភាពក្នុងស្រុក និងលទ្ធភាពសងរបស់សមភាគី។ បម្រែបម្រួលទាំងនេះរួមមាន ការផ្លាស់ប្តូរនៃបរិស្ថានបច្ចេកវិទ្យា សេដ្ឋកិច្ច ទីផ្សារ ច្បាប់ និងសង្គម

៤. សូចនាករហានិភ័យប្រទេសដែលអាចមានឥទ្ធិពលអវិជ្ជមានលើស្ថានភាពរបស់សមភាគី។

**ប្រការ ៦៤.-**

ការវាយតម្លៃអ៊ីមភែរមិននៃហ្វាស៊ីលីធី ត្រូវអនុវត្តឱ្យមានសង្គតិភាពតាមគ្រានីមួយៗ។ រាល់ការផ្លាស់ប្តូរគោលនយោបាយ និងនីតិវិធី ត្រូវកែសម្រួល និងអនុម័តដោយគណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល។

**ប្រការ ៦៥.-**

គ្រឹះស្ថានត្រូវកំណត់កម្រិតនៃការធ្វើសំវិធានធនដោយប្រុងប្រយ័ត្នដើម្បីរ៉ាប់រងការខាតបង់ដែលអាចបណ្តាលមកពីហានិភ័យឥណទាន។ ការខាតបង់នេះ រាប់បញ្ចូលទាំងការខាតបង់ដែលមានរួចហើយ ប៉ុន្តែមិនទាន់ត្រូវបានកំណត់អត្តសញ្ញាណ ឬចាត់ថ្នាក់ក្នុងហ្វាស៊ីលីធីទោល ឬហ្វាស៊ីលីធីក្រុម។ ការអនុវត្តនេះមានសារៈសំខាន់នៅពេលមានស្ថានភាពឥណទានមិនល្អកើតឡើង ប៉ុន្តែមិនបានរាយការណ៍នៅពេលធ្វើការវាយតម្លៃ ឬនៅកាលបរិច្ឆេទនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ជំពូកទី ៨
## ការធ្វើសំវិធានធនតាមស្តង់ដារគណនេយ្យ

**ប្រការ ៦៦.-**

នៅពេលហ្វាស៊ីលីធីត្រូវបានចាត់ថ្នាក់ថាមានអ៊ីមភែរមិន ទោះជាតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម" គ្រឹះស្ថានត្រូវបង្កើនសំវិធានធនជាក់លាក់ ដើម្បីរ៉ាប់រងកង្វះលំហូរសាច់ប្រាក់ដែលអាចកើតមាននៅពេលដល់កាលកំណត់សងតាមកិច្ចសន្យា។ ការបង្កើនសំវិធានធននេះត្រូវរួមបញ្ចូលសោហ៊ុយ និងចំណាយផ្សេងៗដែលកើតមាន ដើម្បីទទួលបានលំហូរសាច់ប្រាក់មកវិញ។ ការធ្វើសំវិធានធនជាក់លាក់ត្រូវបានរាយការណ៍តាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម" ប្រសិនបើការវាស់វែងអ៊ីមភែរមិននៃហ្វាស៊ីលីធី ត្រូវបានវាយតម្លៃដោយផ្អែកតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម" រៀងគ្នា។

**ប្រការ ៦៧.-**

នៅពេលគណនាសំវិធានធនជាក់លាក់សម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន គ្រឹះស្ថានត្រូវវាយតម្លៃដោយផ្អែកលើលក្ខណៈ "ហ្វាស៊ីលីធីទោល"។ ហ្វាស៊ីលីធីដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា និងស្ថិតក្រោមកម្រិតកំណត់ជាសារវន្ត ត្រូវបានបញ្ចូលគ្នានិងវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ដូចមានចែងក្នុងប្រការ ៥០ នៃប្រកាសនេះ។

ជាផ្នែកមួយនៃការពិនិត្យឥណទានឡើងវិញ គ្រឹះស្ថានត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីទំហំហ្វាស៊ីលីធីដែលត្រូវយកមកវាយតម្លៃតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ដើម្បីចែកឲ្យដាច់ថាហ្វាស៊ីលីធីដែលមានតម្លៃក្រោមកម្រិតកំណត់ អាចត្រូវបានចាត់ក្នុងក្រុមដែលមានលក្ខណៈប្រហាក់ប្រហែល ក្នុងគោលបំណងវាយតម្លៃអ៊ីមភែរមិននៃហ្វាស៊ីលីធី។ គ្រឹះស្ថានត្រូវធានាថា រាល់ហ្វាស៊ីលីធីទាំងអស់ក្នុងសំពៀតឥណទានត្រូវបានពិនិត្យឡើងវិញតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ឬ "ហ្វាស៊ីលីធីក្រុម"។

ការធ្វើសំវិធានធនជាក់លាក់បន្ថែមត្រូវធ្វើឡើងដោយផ្អែកលើការវាយតម្លៃបន្ថែមតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ដូចមានចែងក្នុងប្រការ ៥១ នៃប្រកាសនេះ។

**ប្រការ ៦៨.-**

ការធ្វើសំវិធានធន ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដែលធ្វើឡើងតាមលក្ខណៈ "ហ្វាស៊ីលីធីទោល" ត្រូវផ្អែកលើការប៉ាន់ស្មានសមហេតុផលនិងមានឯកសារគ្រប់គ្រាន់ អំពីតម្លៃបច្ចុប្បន្ននៃហ្វាស៊ីលីធី និងការទូទាត់នាពេលអនាគតនៃប្រាក់ដើម ការប្រាក់ និងលំហូរសាច់ប្រាក់ផ្សេងៗទៀត ដែលគ្រឹះស្ថានរំពឹងថានឹង

ទទួលបានពីហ្វាស៊ីលីធីនោះ។ ហ្វាស៊ីលីធីធំៗ ត្រូវបានវាយតម្លៃតាមវិធីសាស្ត្រដែលមានលក្ខណៈជឿនលឿន ដូចជាការប្រើប្រាស់ម៉ូដែល និងបច្ចេកទេសស្ថិតិផ្សេងៗទៀត។

**ប្រការ ៦៩**.-

ការធ្វើសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ត្រូវផ្អែកលើបទពិសោធន៍នៃប្រវត្តិខាតបង់ហ្វាស៊ីលីធីរបស់គ្រឹះស្ថាន ដែលត្រូវកែសម្រួលដូចមានចែងក្នុងប្រការ ៥៩ នៃប្រកាសនេះ ឲ្យបានសមស្របតាមស្ថានភាព លក្ខខណ្ឌនានាពេលបច្ចុប្បន្ន និងកត្តាផ្សេងទៀត ដែលអាចមានឥទ្ធិពលលើការទូទាត់សងហ្វាស៊ីលីធីក្នុងសំពៀតឥណទាន។ ការធ្វើសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" ត្រូវប្រើប្រាស់បច្ចេកទេសជឿនលឿន ដែលអាចជួយដល់ការប៉ាន់ស្មានអ៊ីមភែរមិននៃហ្វាស៊ីលីធីកាន់តែច្បាស់លាស់។

គ្រឹះស្ថានត្រូវរក្សាឲ្យបានគ្រប់គ្រាន់នូវទិន្នន័យនៃប្រវត្តិខាតបង់ហ្វាស៊ីលីធីសម្រាប់រយៈពេលមួយវដ្តឥណទាន ដើម្បីប៉ាន់ស្មានទំហំអ៊ីមភែរមិននៃហ្វាស៊ីលីធីឲ្យបានត្រឹមត្រូវនិងអាចទុកចិត្តបានក្នុងការកំណត់ទំហំសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" សម្រាប់ក្រុមនីមួយៗនៃហ្វាស៊ីលីធីដែលមានលក្ខណៈស្រដៀងគ្នា។

**ប្រការ ៧០**.-

ការធ្វើសំវិធានធន ក៏ត្រូវផ្អែកលើការវិនិច្ឆ័យប្រកបដោយបទពិសោធន៍ផ្នែកឥណទាន ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥៨ នៃប្រកាសនេះ។

**ប្រការ ៧១**.-

ដើម្បីកំណត់កម្រិតសមស្របនៃការធ្វើសំវិធានធនតាមលក្ខណៈ "ហ្វាស៊ីលីធីក្រុម" គ្រឹះស្ថានត្រូវបែងចែកសំពៀតហ្វាស៊ីលីធីទៅជាក្រុមតូចៗតាមការចាំបាច់ ទៅតាមចរិតលក្ខណៈស្រដៀងគ្នា ដូចជាប្រភេទហ្វាស៊ីលីធី ចំណាត់ថ្នាក់ហានិភ័យ ឥណប្រតិទាន ស្ថានភាពហួសកាលកំណត់សង ប្រភេទអតិថិជន និងប្រភេទទ្រព្យធានា ជាដើម។

## ជំពូកទី ៩
## ការធ្វើសំវិធានធនតាមបទប្បញ្ញត្តិ

**ប្រការ ៧២**.-

ការធ្វើសំវិធានធនតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ៧២ ដល់ប្រការ ៧៣ នៃប្រកាសនេះ ត្រូវចាត់ទុកជាកម្រិតគោលនៃសំវិធានធន ដែលគ្រឹះស្ថានបានគណនាត្រឹមត្រូវនិងសមស្របសម្រាប់តាមដានផ្នែកបទប្បញ្ញត្តិនូវកម្រិតសំវិធានធនលើហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ៤៩ ដល់ប្រការ ៧១ នៃប្រកាសនេះ។

ការគណនាកម្រិតសំវិធានធនសរុបតាមបទប្បញ្ញត្តិ ស្មើនឹងខ្ទង់ ១ + ២ ដែលក្នុងនោះ៖

១. សំវិធានធនទូទៅ ស្មើនឹង ១% នៃហ្វាស៊ីលីធីដុល ដែលបានចាត់ថ្នាក់ "ធម្មតា"

២. សំវិធានធនជាក់លាក់ ស្មើនឹង ក + ខ + គ + ឃ

ក = ៣% នៃហ្វាស៊ីលីធីដុល សម្រាប់ហ្វាស៊ីលីធីចាត់ថ្នាក់ "ឃ្លាំមើល"

ខ = ២០% នៃហ្វាស៊ីលីធីដុល សម្រាប់ហ្វាស៊ីលីធីចាត់ថ្នាក់ "ក្រោមស្តង់ដារ"

គ = ៥០% នៃហ្វាស៊ីលីធីដុលសម្រាប់ហ្វាស៊ីលីធីចាត់ថ្នាក់ "សង្ស័យ"

ឃ = ១០០% នៃហ្វាស៊ីលីធីដុល សម្រាប់ហ្វាស៊ីលីធីចាត់ថ្នាក់ "បាត់បង់"

គ្រឹះស្ថានត្រូវធ្វើចំណាត់ថ្នាក់ហានិភ័យឥណទានចំពោះសំពៀតហ្វាស៊ីលីធីទាំងអស់ស្របតាមបញ្ញត្តិនៃប្រការ ១២ ដល់ ប្រការ ២២ នៃប្រកាសនេះ ដើម្បីឱ្យគ្រឹះស្ថានអាចកំណត់កម្រិតសំវិធានធនតាមបទប្បញ្ញត្តិតាមស្ថានភាពជាក់ស្តែងនៃសំពៀតហ្វាស៊ីលីធី។ សំវិធានធនតាមបទប្បញ្ញត្តិ ត្រូវចាត់ទុកជាចំនួនអប្បបរមានៃសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។

ការធ្វើសំវិធានធនតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងបញ្ញត្តិនៃប្រការ ៧២ ដល់ប្រការ ៧៣ នៃប្រកាសនេះ ត្រូវធ្វើឡើងទន្ទឹមនឹងការគណនាកម្រិតសំវិធានធនលើហ្វាស៊ីលីធី ដែលមានអ៊ីមភែរមិន ដែលមានចែងក្នុងបញ្ញត្តិនៃប្រការ ៤៩ ដល់ប្រការ ៧១ ខាងលើ ដែលជាកាតព្វកិច្ចសម្រាប់គ្រប់គ្រឹះស្ថានទាំងអស់។

**ប្រការ ៧៣**.-

គ្រឹះស្ថានត្រូវប្រៀបធៀប កម្រិតសំវិធានធនគណនាតាមបញ្ញត្តិនៃប្រការ ៤៩ ដល់ប្រការ ៧១ និងកម្រិតសំវិធានធនតាមបទប្បញ្ញត្តិដែលគណនាតាមប្រការ ៧២ ហើយត្រូវកត់ត្រាចំនួនសំវិធានធន ដូចខាងក្រោម៖

១. ក្នុងករណីកម្រិតសំវិធានធនដែលគណនាតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ៧២ **<u>ទាបជាង</u>** កម្រិតសំវិធានធនដែលគណនាតាមបញ្ញត្តិនៃប្រការ ៤៩ ដល់ប្រការ ៧១ គ្រឹះស្ថានត្រូវកត់ត្រាសំវិធានធនដែលគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា។

២. ក្នុងករណីកម្រិតសំវិធានធនដែលគណនាតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ៧២ **<u>ខ្ពស់ជាង</u>** កម្រិតសំវិធានធនដែលគណនាតាមបញ្ញត្តិនៃប្រការ ៤៩ ដល់ប្រការ ៧១ គ្រឹះស្ថានត្រូវកត់ត្រាសំវិធានធនដែលគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា ហើយត្រូវផ្ទេរចំនួនខុសគ្នា (the difference) ពីគណនីប្រាក់ចំណេញរក្សាទុកឬខាតបង្គរទៅក្នុងគណនី "ទុនបម្រុងតាមបទប្បញ្ញត្តិ" (Regulatory Reserve) ក្នុងខ្ទង់មូលនិធិភាគទុនិកនៃតារាងតុល្យការ។

ទុនបម្រុងតាមបទប្បញ្ញត្តិនេះមិនត្រូវអនុញ្ញាតឱ្យបូកបញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានទេ។

**ប្រការ ៧៤**.-

ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន ត្រូវចាត់វិធានការសមស្របដើម្បីធានាបានការអនុវត្តពេញលេញតាមលក្ខខណ្ឌនានានៃប្រកាសនេះ។

## ជំពូកទី ១០
## ការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី

**ប្រការ ៧៥**.-

ក្នុងការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី គ្រឹះស្ថានត្រូវផ្អែកលើការវាយតម្លៃយ៉ាងហ្មត់ចត់អំពីលទ្ធភាពសងរបស់សមភាគី និងការវិភាគលើស្ថានភាពអាជីវកម្មនិងហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ពីសកម្មភាពអាជីវកម្មនោះ ស្របតាមក្របខ័ណ្ឌនៃការចាត់ថ្នាក់ដូចមានចែងក្នុងបញ្ញត្តិនៃប្រការ ១២ ដល់ ប្រការ ២២ នៃប្រកាសនេះ។

**ប្រការ ៧៦**.-

គ្រឹះស្ថានអាចស្តារចំណាត់ថ្នាក់ហ្វាស៊ីលីធីពីហ្វាស៊ីលីធីមិនដំណើរការ ទៅជា ហ្វាស៊ីលីធីដំណើរការ និងត្រូវបំពេញតាមលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម៖

១. ហ្វាស៊ីលីធីវិវត្តទៅរកស្ថានភាពដែលបានអនុវត្តគ្រប់លក្ខខណ្ឌនៃកិច្ចសន្យាដើម រួមទាំងការទទួលបានការទូទាត់សងប្រាក់ដើម ការប្រាក់ និងសោហ៊ុយផ្សេងៗដែលហួសកាលកំណត់សង

២. គ្រឹះស្ថានមានហេតុផលសមស្របក្នុងការជឿជាក់ថាសមភាគីនឹងបំពេញតាមកាតព្វកិច្ចទូទាត់សងនាពេលអនាគត

៣. ហ្វាស៊ីលីធីដែលខកខានសងហួសរយៈពេល ៩០ ថ្ងៃ ឬលើសពីនេះ (៦០ ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី) ត្រូវបានទូទាត់សងវិញទាំងអស់ ហើយការទូទាត់សងនេះ ត្រូវធ្វើឡើងដោយមិនប្រើប្រាស់ការធ្វើបុរេប្រទានបន្ថែមពីគ្រឹះស្ថាន។ ចំពោះហ្វាស៊ីលីធីដែលបង់រំលស់ប្រចាំខែ សមភាគីបានអនុវត្តតាមកាតព្វកិច្ចទូទាត់សងបន្តបន្ទាប់គ្នាក្នុងរយៈពេលយ៉ាងតិច ០៦ ខែ (០៣ ខែសម្រាប់ហ្វាស៊ីលីធីរយៈពេលខ្លី)។ គ្រឹះស្ថានមិនត្រូវស្តារចំណាត់ថ្នាក់ហ្វាស៊ីលីធីនោះទេ ប្រសិនបើគ្រឹះស្ថានសង្ស័យថា ការទូទាត់សងរបស់សមភាគីបានមកពីបុរេប្រទានពីគ្រឹះស្ថានផ្សេងៗ ឬបុគ្គលណាមួយ។ ក្នុងករណីណាក៏ដោយ គ្រឹះស្ថានត្រូវធានាថា សមភាគីមានលទ្ធភាពទូទាត់សងបន្ថែមទៀតលើសពីការតម្រូវ (Margin of comfort) ដែលអាចការពារមិនឲ្យហ្វាស៊ីលីធីវិវត្តទៅស្ថានភាពមិនដំណើរការវិញនាពេលអនាគត បើមិនដូច្នោះទេ ហ្វាស៊ីលីធីនេះនៅតែត្រូវបានចាត់ថ្នាក់ជាហ្វាស៊ីលីធីមិនដំណើរការដដែល

៤. ហ្វាស៊ីលីធីដែលត្រូវបានលុបចោលមួយផ្នែក ត្រូវបានទូទាត់សងវិញជាបន្តបន្ទាប់ក្នុងរយៈពេលយ៉ាងតិច ០៦ ខែ ឬយ៉ាងតិច ០៣ គ្រា

៥. ចំពោះហ្វាស៊ីលីធីដែលតម្រូវឲ្យធ្វើសំវិធានធនដោយសារហេតុផលសមស្របណាមួយ សំវិធានធននោះមិនតម្រូវទៀតទេ និង

៦. ចំពោះហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញ (Revolving Facilities) ដោយមិនមានការធានាគ្រប់គ្រាន់ និងត្រូវបានប្រើប្រាស់លើសកម្រិតកំណត់ ហ្វាស៊ីលីធីត្រូវវិវត្តមកត្រឹមកម្រិតអនុម័តវិញក្នុងរយៈពេលបន្តបន្ទាប់យ៉ាងតិច ០៣ ខែ។

**ប្រការ ៧៧.-**

គ្រឹះស្ថានត្រូវអនុវត្តដោយប្រុងប្រយ័ត្នក្នុងការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធីពីមួយថ្នាក់ទៅមួយថ្នាក់ និងត្រូវធានាថា ហ្វាស៊ីលីធីដែលគ្រឹះស្ថានមានបំណងតម្លើងចំណាត់ថ្នាក់ បង្ហាញនិន្នាការវិវត្តទៅរកភាពល្អប្រសើរជាលំដាប់ និងគោរពតាមរាល់លក្ខខណ្ឌនៃការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី។

**ប្រការ ៧៨.-**

រាល់ការតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី គ្រឹះស្ថានត្រូវមានឯកសារភស្តុតាងច្បាស់លាស់ជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តក្នុងការតម្លើងចំណាត់ថ្នាក់នោះ។ គ្រឹះស្ថានត្រូវរាយការណ៍ពីការតម្លើងចំណាត់ថ្នាក់តាមគ្រាជូនក្រុមប្រឹក្សាភិបាល ហើយរបាយការណ៍នោះអាចប្រើប្រាស់បានដោយ សវនករផ្ទៃក្នុង ក្រុមហ៊ុនសវនកម្ម និងធនាគារជាតិនៃកម្ពុជាតាមការចាំបាច់។

**ប្រការ ៧៩.-**

នៅពេលហ្វាស៊ីលីធីមិនដំណើរការត្រូវបានតម្លើងចំណាត់ថ្នាក់ជាហ្វាស៊ីលីធីដំណើរការ ហើយបន្ទាប់មកក្លាយជាហ្វាស៊ីលីធីមិនដំណើរការម្តងទៀត គ្រឹះស្ថានមិនអាចតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធីនោះ ជាលើកទីពីរបានទេ។ គ្រឹះស្ថានត្រូវរក្សាហ្វាស៊ីលីធីនោះជាហ្វាស៊ីលីធីមិនដំណើរការដដែល។

**ប្រការ ៨០.-**

បន្ថែមទៅលើបញ្ញត្តិនៃប្រការ ៦០ នៃប្រកាសនេះ គ្រឹះស្ថានមិនអាចបំបែកហ្វាស៊ីលីធីតែមួយទៅជាផ្នែកដែលមិនដំណើរការផង និងផ្នែកដំណើរការផងបានទេ។

**ប្រការ ៨១.-**

ហ្វាស៊ីលីធីដែលត្រូវបានរៀបចំឡើងវិញរួចហើយ មិនត្រូវបានចាត់ថ្នាក់ឲ្យល្អជាងមុនទេ លុះត្រាតែសមភាគីបានគោរពពេញលេញតាមលក្ខខណ្ឌនៃកិច្ចសន្យាហ្វាស៊ីលីធីរៀបចំឡើងវិញ និងបានអនុវត្តដូចខាងក្រោម៖

១. បានទូទាត់សងគ្រប់ចំនួន ទាំងប្រាក់ដើមនិងការប្រាក់ យ៉ាងតិចក្នុងរយៈពេល ០៦ ខែ ចំពោះហ្វាស៊ីលីធីដែលត្រូវទូទាត់សងប្រចាំខែ ឬ

២. បានទូទាត់សងគ្រប់ចំនួន ទាំងប្រាក់ដើមនិងការប្រាក់ យ៉ាងតិចក្នុងរយៈពេល ០១ ឆ្នាំ ចំពោះហ្វាស៊ីលីធីដែលត្រូវទូទាត់សងប្រចាំត្រីមាស ឬឆមាស។

ក្នុងករណីហ្វាស៊ីលីធីរៀបចំឡើងវិញដែលមានការទូទាត់សងប្រាក់ដើមនិងការប្រាក់ប្រចាំឆ្នាំ ឬរយៈពេលវែងជាង គ្រឹះស្ថានអាចតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធីបាន លុះត្រាតែសមភាគីបានគោរពពេញលេញតាមលក្ខខណ្ឌកិច្ចសន្យានៃហ្វាស៊ីលីធីរៀបចំឡើងវិញ ហើយបានបង្ហាញពីលទ្ធភាពទូទាត់សង បន្ទាប់ពីបញ្ចប់ការទូទាត់សងលើកទីមួយ។ គ្រឹះស្ថានមិនត្រូវតម្លើងចំណាត់ថ្នាក់ហ្វាស៊ីលីធី មុនពេលសមភាគីធ្វើការសងរំលស់លើកទីមួយទាន់ពេលនិងគ្រប់ចំនួន។

ក្នុងករណីដែលហ្វាស៊ីលីធីរៀបចំឡើងវិញត្រូវបានផ្ដល់រយៈពេលអនុគ្រោះ (Moratorium) គ្រឹះស្ថានមិនត្រូវតម្លើងចំណាត់ថ្នាក់ក្នុងអំឡុងពេលអនុគ្រោះនោះទេ។ ការតម្លើងចំណាត់ថ្នាក់នេះអាចធ្វើបាន លុះត្រាតែសមភាគីគោរពទៅតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការនេះ ដោយថ្ងៃចាប់ផ្ដើមត្រូវគិតចាប់ពីថ្ងៃបញ្ចប់រយៈពេលអនុគ្រោះ។

**ប្រការ ៨២.-**

ក្នុងករណីហ្វាស៊ីលីធីរៀបចំឡើងវិញចំពោះហ្វាស៊ីលីធីដើមដែលត្រូវបានចាត់ថ្នាក់ជាហ្វាស៊ីលីធីមិនដំណើរការ ដូចជា "ក្រោមស្ដង់ដារ" "សង្ស័យ" ឬ "បាត់បង់" រួចហើយ គ្រឹះស្ថានមិនត្រូវចាត់ថ្នាក់ហ្វាស៊ីលីធីទាំងនោះឲ្យល្អជាង "ក្រោមស្ដង់ដារ" ទេ។ ក្នុងករណីណាក៏ដោយ ហ្វាស៊ីលីធីដែលត្រូវបានរៀបចំឡើងវិញលើសពីមួយដង មិនអាចតម្លើងចំណាត់ថ្នាក់បានទេ។

## ជំពូកទី ១១
## ការលុបចោលហ្វាស៊ីលីធី

**ប្រការ ៨៣.-**

ក្រុមប្រឹក្សាភិបាលត្រូវអនុម័តលើគោលនយោបាយលុបចោលហ្វាស៊ីលីធី ហើយគោលនយោបាយនេះត្រូវមានចែងអំពី កាលៈទេសៈ លក្ខខណ្ឌ និងសិទ្ធិអនុម័ត ក្នុងការលុបចោលហ្វាស៊ីលីធីទាំងនោះ។ គោលនយោបាយនេះ ត្រូវកំណត់អំពីចរិតលក្ខណៈ និងគ្រារាយការណ៍អំពីការលុបចោលហ្វាស៊ីលីធី ជូនក្រុមប្រឹក្សាភិបាល។ ការរាយការណ៍នេះត្រូវមានព័ត៌មានត្រឹមត្រូវអំពីការខិតខំប្រឹងប្រែងប្រមូលហ្វាស៊ីលីធីមកវិញ មុនពេលសម្រេចលុបចោលហ្វាស៊ីលីធីនោះ។

**ប្រការ ៨៤.-**

ជាគោលការណ៍ គ្រឹះស្ថានត្រូវដកចេញហ្វាស៊ីលីធីផ្នែកខ្លះឬទាំងស្រុងចេញពីតារាងតុល្យការនៅពេលគ្រឹះស្ថានបាត់បង់ការគ្រប់គ្រងលើសិទ្ធិ ដូចមានចែងក្នុងកិច្ចសន្យានៃហ្វាស៊ីលីធីនោះ ឬនៅពេលហ្វាស៊ីលីធីនោះផ្នែកខ្លះឬទាំងស្រុង មិនរំពឹងថាអាចប្រមូលមកវិញបាន ជាពិសេស ក្នុងករណីដែលហ្វាស៊ីលីធីនោះមិនប្រាកដថានឹងអាចប្រមូលមកវិញបាន ឬនៅពេលគ្រឹះស្ថានបាត់បង់ការគ្រប់គ្រងលើសិទ្ធិដូចមានចែងក្នុង

កិច្ចសន្យានៃហ្វាស៊ីលីធី ដោយសារសេចក្ដីសម្រេចរបស់តុលាការ។ ហ្វាស៊ីលីធីអាចត្រូវបានលុបចោលក្នុងករណីណាមួយយ៉ាងតិចដូចខាងក្រោម៖

១. ការធានា ឬទ្រព្យធានាគ្រប់ប្រភេទ ត្រូវបានបញ្ចប់ និងបានលក់ចេញ ប៉ុន្តែទឹកប្រាក់ដែលលក់បានមិនអាចទូទាត់សងគ្រប់សមតុល្យដក់សល់របស់ហ្វាស៊ីលីធី

២. គ្រឹះស្ថានមិនអាចប្រមូល ឬមិនមានមូលហេតុសមស្របក្នុងការធានាថានឹងប្រមូលបានគ្រប់ចំនួនដែលដល់កាលកំណត់សង ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាហ្វាស៊ីលីធី

៣. សមភាគីបានក្ស័យធន ឬស្ថិតក្នុងដំណាក់កាលរៀបចំឡើងវិញផ្នែកហិរញ្ញវត្ថុ ដែលលទ្ធផលនៃការរៀបចំឡើងវិញនេះ មិនអាចទូទាត់សងហ្វាស៊ីលីធីបាន ឬ

៤. ហ្វាស៊ីលីធីត្រូវបានចាត់ថ្នាក់ថា "បាត់បង់"។

## ជំពូកទី ១២
## ការត្រួតពិនិត្យ

**ប្រការ ៨៥.-**

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ កែសម្រួលគោលការណ៍និងនីតិវិធី និងលទ្ធផលនៃការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធី ការវាយតម្លៃហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងការធ្វើសំវិធានធនចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន។ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ ត្រូវចាត់វិធានការកែតម្រូវភ្លាមៗឱ្យបានសមស្រប។

## ជំពូកទី ១៣
## អន្តរប្បញ្ញត្តិ

**ប្រការ ៨៦.-**

គ្រឹះស្ថានត្រូវត្រៀមខ្លួនអនុវត្តការទទួលស្គាល់ ការវាស់វែង និងការធ្វើសំវិធានធនរបស់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា ដែលគ្រោងនឹងចាប់ផ្ដើមអនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។

**ប្រការ ៨៧.-**

ក្នុងរយៈពេលអន្តរកាលមុនឈានទៅការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា គ្រឹះស្ថានត្រូវធ្វើសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន ស្របតាមប្រការ ៧២ នៃប្រកាសនេះ។

បន្ទាប់ពីអនុវត្តបានពេញលេញតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា គ្រឹះស្ថានត្រូវអនុវត្តតាមប្រការ ៧៣ នៃប្រកាសនេះ ចំពោះការធ្វើសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្នុងករណីគ្រឹះស្ថានមានបំណងអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជាមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ គ្រឹះស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ១៤
## អវសានប្បញ្ញត្តិ

**ប្រការ ៨៨.-**

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៨៩.-**

ប្រកាសលេខ ធ៧-០៩-០៧៤ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការធ្វើចំណាត់ថ្នាក់និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសលេខ ធ៧-០២-១៨៦ ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ ស្តីពី ចំណាត់ថ្នាក់និងសំវិធានធនលើឥណទានអនុវត្តចំពោះធនាគារឯកទេស ឥណទានជនបទនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩០.-**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដែលមានការពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩១.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១៣ កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ គ.ស ២០១៧

**ទេសាភិបាល**

ជា_ចាន់តូ

**កន្លែងទទួល៖**

- ដូចប្រការ ៩០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"